# រឿងស្ពាងចំប៉ាថោង

ក័ណ្ឌ ៣



# សៀវភៅដែលផ្សាយចេញពីគេហស្ថាន គីម-គី

| | | |
|---|---|---|
| ច្បាប់បរឡាន . . . . . . . . . . . | ១ សៀវភៅថ្លៃ | ១០៛០០ |
| ព្រះគោព្រះកែវ ទី ១ ដល់ទី ៧ ចប់ . . . | ,, | ៨៛០០ |
| តេជោដំឌិន ទី ១ ដល់ទី ៧ ចប់ . . . . . | ,, | ៨៛០០ |
| ទឹកកុំផ្កាក ទី ១ ទី ២ ចប់ . . . . . . | ,, | ៨៛០០ |
| កាព្យកំសាន្តចិត្ត . . . . . . . . . . | ,, | ៦៛០០ |
| រឿងធនូមឿង ទី ១ ទី ២ ចប់ . . . . . | ,, | ៨៛០០ |
| រឿងធ្មេញជ័យ . . . . . . . . . . | ,, | ១២៛០០ |
| រឿងអាឡាដាំងមនុស្សម្នាក់ទិញចង្កៀងទិព្វ | ,, | ១៤៛០០ |
| រឿងព្រះសុធន នាងកែវមនោរា ទី ១ ទី ២ ចប់ | ,, | ៩៛០០ |
| រឿងវិបុលសង្គ្រាមទី ១ . . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ២ . . . . . . . | ,, | ១៤៛០០ |
| ,, ,, ទី ៣ . . . . . . . | ,, | ១២៛០០ |
| នាងពីរដណ្ដប់ ពុទ្ធិសែនឆាឆ័កគ្រី . . . | ,, | ១០៛០០ |
| ព្រះបន្ទូរគោរប់ ទី ១ ទី ២ . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ៣ ចប់ . . . . . . | ,, | ១២៛០០ |
| កុមារផ្កាទ . . . . . . . . . . | ,, | ១០៛០០ |
| រឿងតាឯក ទី ១ ទី ២ ទី ៣ ទី ៤ . . . | ,, | ៤៛០០ |
| សេកសារិកា . . . . . . . . . . | ,, | ៧៛០០ |
| រឿងជ័យសុរិន្ទ ទី ១ ដល់ទី ៤ ចប់ . . . | ,, | ១០៛០០ |
| រឿងព្រះមហោសថ ទី ១ . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ២ ទី ៣ . . . . . | ,, | ៨៛០០ |

ARCHIVES NATIONALES
13. 71. 235 86

សំណូមសំណាង ស្តែងស្តេចបានសាង បរមជាតិ
នឹងនាងវរលក្ស ជាអគ្គមហេសី ទេព្តានាំខ្ញី
មកដល់នេះណា ៗ ឱអាសូរក្តាត់ សឹងកំព្រាព្រាត់
ឯកឯងដូចគ្នា គូរគូស្មោះស្មើ លើសលើលោកា
ទ្រង់ទ្រាយឆាយា សោតសំប្រៃពៃ ៗ គាល្អោះវឡា
ដឹងដោយកបា អរឯងគេតក្រែ បំអកបំអន់
ស្រីតនថ្លាថ្លៃ ថាឱះឪថ្ងៃ នេះហើយខ្ញុំឆ្ងល់ ៗ
នឹងអ្នកម្ចាស់ថ្លៃ ថ្លៃកជាងសព្វថ្ងៃ ដោយក្អកខ្ញុំយល់
ប្រិមប្រិកគ្រា សោភានិមល ដូចចន្ទពេញបុល
រុងរឿងជ្រះថ្លា ៗ យល់ថាទូវមាន ហោកលទមិនខាន
បើដោយខ្ញុំថា ម្ទះហើយបើបាន រួមស្មានស្នេហា
នឹងក្រួបខ្ញុំជា ខ្ញុំអ្នកម្ចាស់ថ្លៃ ៗ នាងស្តាប់វីឡា
ពោលពាក្យបរបារ បំអន់នាងនៃ ព្រះឱស្ឋប៉ប្រិម
ញញឹមបប្រៃ ត្រេកត្រស់ថាហៃ នៃនាងវីឡា ៗ
ម្តេចឡើយបេះដាង ចរចារកសកង បំអកអញណោ
តើអញបានដឹង ដំណឹងតិចព សោះសូន្យម្តេចថា
ឲ្យអាស្រូវប្ចេះ ៗ ធ្វើគល់គិបាយ ថានាយថាអាយ
ហ៊ានហួសដល់ម្ទេរ នាងឯងហ៊ានយក ប្រុសមកនៅនេះ
ហើយគាប់ចែបេះ បញ្ជ្រះជ្រែងជ្រែ ៗ ប៉ុនប៉ងបន់បាន

ផាប្តីហើយហ៊ាន ថាមកឯគេ ឡូកឡឺយបរិយាយ
នាយគាយបំបែ ត្រង់អញៗទេ អញមិនដឹងផង ។
វិឡាសោកសើច អរអស់សំណើច ទូលទៅវិញស្នង
ថាបើម្ចាស់ផ្សំ ទឹងខ្ញុំនេះម្តង ខ្ញុំអរក្តាត់ហោង
បានប្តីក្សត្រា ។ រុងតែបើបាន វិលវិញមកឋាន
ដូចទ្រង់ប្រាថ្នា បើត្រូវត្រង់ខ្ញុំ ខ្ញុំពុំបរហារ
បើដូចខ្ញុំថា គិតម្តេចនេះម្តង ។ នាងសុវណ្ណា
ស្តាប់ពាក្យវិឡា ចំអកលេងលង់ នាងធ្វើជាក្រោធ
កំរោធក្តាត់ហោង ពុំត្រាស់សួរសង ស្ងៀមស្ងាត់វាចា ។
វិឡាស្តីដោះ ទោសតែប៉ុណ្ណោះ អ្នកមាសកំងរ
មាត់មិតទទួល សងសួរឡើយណា ខ្ញុំៗមហា
ថប់ពន់ប្រមាណ ។ ទុះបើទឹងខុស ទោសទាល់ស្លាប់រស់
ម្តេចៗលេងបាន ម្ចាស់ពីរព្រះអង្គ ត្រូវគង់រួមស្ថាន
មួយក្រោធមួយក្បួទ នោះមិនជាអ្វី ។ នេះម្តងខាល់ពេក
ពុំដឹងបើផ្អែក ឥតអង្គចក្រ មានតែពិតា
អ្នកជាក្សត្រី ក្រៅក្រឥតបី នូវពឹងអ្នកណា ។
នាងស្តាប់សំដី ពាក្យវិឡាវៃ បែងបេះបរហារ
ខ្ញាសឯងរៀនអន់ ស្រពោនកក្តា ធ្វើពុំនាំពារ
គង់ស្ងៀមកន្តើយ ។ វីងព្រះបាទ ស្តែងស្តេចឃ្លាឃ្លាត

ពុំផ្សងផ្សើទៀយ　គ្រែបដោយមាគា　ក្សត្រាត្រានត្រើយ
អាទៀតតសៀយ　ពីព្រះពន្ធិតា ។　ឯអស់យក្សយង់
តាមហៃព្រះអគ្គ　ក្រាស់ក្រៃត្រៀមត្រា　ទ្រមេញទ្រមើម
គួរល្អើមគ្គាត់ណា　រូបរូបពុតា　ផាតធំស្កឹមស្កៃ ។
សឹងមានបេស្តា　ដើរដល់ស្ពានណា　ល្អិតល្អបព្រិក្សព្រៃ
រង្គោះរង្គិ　រលំដល់ដី　ល្អិតពបរិសៃ
ព្រះលានសោះសា ។　ស្តេចពុំឈរឈប់　កន្ទុះចិត្តគ្រប់
ដល់បុរីសេមា　ស្តេចបើកព្រះសូរ　បន្ទូលក្រាស់ថា
ហៃអស់ទាំងគ្នា　យើងយក្សនេះម្តង ។　ឥឡូវមកដល់
ព្រំព្រះមណ្ឌល　ហេមន្តហើយហោង　ចូរអស់យក្សា
យាត្រាវិលផ្គង　ទៅទូលក្សត្របង　ដោយដំណើរណា ។
បើទឹងតាមទៅ　ឡើងដល់លំនៅ　ក្រៃនឹងអ្នកកាក
ទឹងកើតផ្អើលផ្អូក　ក្លឹកក្លូកមហិមា　ដោយតេជះយក្សា
សោកសឹងខ្លាចក្រៃ ។　កាលណ្ហោះយក្សា　ស្តាប់ព្រះរាជា
ត្រេកត្រាស់ស្ងួម៉ៃ　បង្គំក្រាបលា　យាត្រាវិលវៃ
ទៅទូលក្សត្រថ្វៃ　សឹងហុនយក្សា　រីឯព្រះអគ្គ
ស្តែងស្តេចទៀងគង់　លើកដអសុពា　ឯកឯងក្លួរ
ស្តេចចរលើលា　ដោយផងព្រឹក្សា　ពុំឈប់សម្រាន្ត ។
មួយថៃទៀងតាត់　ទើបព្រះមហាក្សត្រ　ព្រះអង្គបរាន

ផល់រាជសោមា យោធាគ្រប់ប្រាណ រុករកក្សត្រក្បួន
សព្វព្រៃព្រឹក្សា ៗ ស្ដេចចូលសំដៅ ឆ្ពោះត្រង់លំនៅ
ទីព្រះពន្លា ស្រេចហើយចុះចាក លះលាក់អសុពា
យល់ប្អូនក្សត្រា ស្ដេចឡើងទៅថ្វាត់ ៗ ព្រះកិលៀងយល់
ស្ដេចស្ដែងមកដល់ ក្រញ៉ក្រាបប្រណិបត្តិ ឱបបាទហើយយំ
សូសុំខ្ញុំងក្ដាត់ ព្រះមាសស្នែស្និទ្ធ អម្ចាស់សិរសា ៗ
បបោសបបក ព្រលឹងថាអ្នក ទៅទិសស្ថានណា
ឲ្យខ្ញុំតែងរង់ ទុក្ខផងខ្លោចផ្សា ស្ទើក្ស័យជន្មា
តែងទន្ទឹងនៅ ៗ ក្បិណ្ណាះព្រះបាទ ដៃជើងទន្ទាច
ធិកជោមហៅ ស្ដេចបើកព្រះសូ បន្ទូលក្រង
ត្រេកត្រាស់ប្រាប់ទៅ កិលៀងក្សត្រា ៗ បងអើយប្អូនឯង
លាក់លះវ៉ាឡើង ព្រៃព្រឹក្សអត្ថា តើបពះយកក្សយន់
ម្រើសទ្រង់ករុណា ឲ្យជូនយាត្រា វិលវិញមកហោង ៗ
អគ្គិសំក្ស័យ ផុតជាតិប្រៃលៃ ពុំមកយល់ហោង
ហើយស្ដេចនិយាយ ប្រាប់ប្រាយទំនង អំពីដើមទង
ដូចមុននោះណា ៗ កិលៀងប្អូនអគ្គ ថ្វាក់ថ្វមក្រញ៉ក្រុង
លួងលោមទូលថា អញ្ជើញព្រះអគ្គ ស្ដេចចរយាត្រា
ពីព្រះរាជា ស្ដេចទន្ទឹងក្ដាត់ ៗ ស្ដេចស្ដាប់ទំនូល
ព្រះកិលៀងទូល កាឡោះក្បិណក្សត្រ ស្រួសកន្ទ៌ម្មា

លីលា ឆាប់ថ្វាត់ ទៀងគន់ពជរត់ ពស់វិរិទ្ធា ៗ
ពលពាលអឹងអរ ហែព្រះភូធរ ចូលក្នុងសេមា
លង់លុះស្តេចផល់ មណ្ឌលប្រាង្គប្រា សាទស្ទួសោភា
ស្តេចបរបុះថ្កាន ៗ ឡើងលើប្រាសាទ ប្រសើរស្អាងស្អាត
ទែនទិព្វពិមាន ឥនសិរបគ្គិ ប្រណម្យក្សត្រក្សាន
ពីក្សត្រប្រធាន ស្តេចទតទៅយល់ ៗ ស្តេចអរឥនឥប
ថ្នាក់ថ្នមក្រសោប បុត្តរត្ននិមល ចូងថ្ងៃសោក្កា
នេត្រាជោរផល់ ហាក់នឹងទប់ទល់ ពិតពុំបានណា ៗ
ហៃស្ងួនឧត្តម ចេញចាកលេងលំ នូវនេះឃ្មោតឃ្មា
ប្រាស់ព្រាត់ព្រឹក្សព្រៃ នោះនៃម្តេចបា បង់បាត់កើតជា
ប្រការគល់អ្វី ៗ បិតាស្មានជា មាសមិញមរណា
គណ្ឌលទូលទី ជីវិតបាត់បង់ នៅក្នុងព្រឹក្សព្រៃ
កីលាពក្រាស់ក្រៃ តែងសោយសោក្កា ៗ តែងតែឧទ្ទឹង
ប្រុសស្ងួនព្រលឹង សព្វទិនទៅ បើយូរលង់ក្រៃ
សំខ្សែភន្ទា កូនឲ្យដង្វិតបា ចបាកនេះម្តង ៗ
ដៃជេតភូមី ក្រញ្ញក្រាបរន្ធី ទើបទូលរំងស្ងួន
បពិត្រក្សត្រា ទ្វហាបង្រះបង្រង កាលកូនបរគ្គង
ប្រាស់ព្រាត់ព្រឹក្សា ៗ ជាលជេញអម្រឹត ល្អះល្អះពន្ទឹក
សឹងសុវណ្ណា តែឯកអគ្គឯង រំងើងមាតា

ព្រាត់ពាយយោធា　មុខមន្ត្រីផង ។　ទូលគាលព្រះបាទ
ព្រះបរមនាថ　ស្តេចត្រេចដោយផង　ព្រះពៃព្រឹក្សា
ឯក្រាកន្ទង　ឥតអ្នកពីរផង　កំដរឡើយណា ។
ទូលគាលព្រះអង្គ　ចូលបតស្រះស្រង់　ពើបពាយក្សា
ទូលគាលក្សត្រក្សត្រ　ដល់ស្ថានជិតា　នាងសុវណ្ណា
ជាបុត្តយក្ខយង　ទូលពីយក្សា　ព្រាត់ព្រមចិន្តា
ឲ្យនាងវរវង្ស　ផ្តាំឲ្យអញ្ជើញ　ក្សត្រទាំងពីរពង្ស
ប្រដាប់កំលុង　រៀបរៀងមាគ៌ា ។　ស្តេចទូលអម្បាល
សព្វគ្រប់អស់អាថ៌　បណ្តាំយក្សា　ព្រះជនកព្រះជនី
ក្សត្រីក្សត្រា　អរឥតគណនា　នឹងបុត្តកល្យាណ ។
ហៃសួនឧត្តម　កុំបារម្ភណ៍　ហេតុបុណ្យប្បារមាន
សាងសូមប្រាថ្នា　កាលគ្រាមុនមាន　មែនមិនដែលខាន
ទើបជួនចេះណា ។　ឪពុកនៅតែង　រៀបចំដំណែង
តាមពាក្យយក្សា　កុំមាសគន់គិត　ព្រួយចិត្តចិន្តា
ឪពុកករុណា　ប្រដាប់ដូចប៉ង ។　ហើយស្តេចប្រញាប់
ត្រេកត្រាសបង្គាប់　មុខមន្ត្រីផង　ឲ្យតែងសាសព្វ
បង្គាប់អ្នកផង　មូលមកហើយហោង　ដូចពាក្យប្រាថ្នា ។
មនុស្សម្នាមហាជន　ក្រាសក្រៃពេកពន់　ណែនណាន់តាក
ហើយទើបឲ្យតែង　ដំណែងមាគ៌ា　ជីកជំរះផ្លា

លើកថ្កល់ស្រាំ ៗ ជីកស្រះជីកត្រួវ សក្ការជាជួរ
ប្របផ្លូវសឹងជាំ ដើមក្រូចស្កុផល របស់ប្រចាំ
តាមព្រះបណ្ដាំ គ្រប់នាយគ្រប់ករ ៗ ហើយវិលទៅទូល
ព្រះបាទឥស្សូរ ធម្មិកប្រះប្រង បពិត្រក្សត្រា
ថ្ងៃថ្មានេះម្ដង វិមាគាផង រួចហើយរាជា ៗ
ស្ដេចស្ដាប់អាមាត្យ ទូលទើបព្រះបាទ មានព្រះឱង្កា
ប្រើអស់សេនីយ៍ ឲ្យតែងរាជសា ទៅប្រាប់ក្សត្រា
ប្រាំបីរយអង្គ ៗ ឲ្យមកម្នីម្នា ជ្រិតព្រះរាជា
ប្រដាប់ការមង្គល គលព្រះរាជបុត្រ វិសុទ្ធវរវង្ស
កុំឲ្យបង្អង់ ខានខុសអាជ្ញា ៗ អាមាត្យនានាំ
ឱង្ការបណ្ដាំ រួសរាន់ម្នីម្នា ដល់ហើយទើបទូល
អស់អង្គក្សត្រា សាយសព្វទិស្សា នគរទទៃ ៗ
ជ្រាបដូច្នោះណា រួតរឹងយាត្រា ទាំងយប់ទាំងថ្ងៃ
ពុលង់ឡើយដល់ មណ្ឌលទិព្វថ្ងៃ ឡើងទៅវៃៗ
បង្គំរាជា ៗ ស្ដេចយល់អស់ក្សត្រិ ប្រាំបីរយថ្វាត់
ដល់ដូចប្រាថ្នា មានព្រះបន្ទូល មធុរះថ្លែងថា
ហៃមហាក្សត្រា ឥឡូវនេះនៃ ៗ ជ្រិតយើងប្រដាប់
ការមង្គលគាប់ ដៃដេតបុត្រថ្ងៃ នូវសុវណ្ណា
សោភាប្រពៃ ជាបុត្រិជៀសដៃ សិងហុនយក្សា

ឥឡូវយើងប្រែង ប្រៀបប្រាណបំរុង ចាំតែពេលា
យើងឲ្យអញ្ជើញ អស់អគ្គក្សត្រា ទៅជួយអាពាហ៍
ពិពាហ៍នេះម្តង ៗ ក្សត្រតាំងប្រាំបី រយទិនអគ្គិ
វន្ទាទូលស្នង យើងខ្ញុំគ្រប់គ្នា នឹងយាត្រាផ្គង
ហៃព្រះប្រះប្រង ឲ្យដល់នាយណា ៗ ព្រមល្មមពុំលង់
ប្រដាប់ព្រះអង្គ ទូវនាងសច្ចា ទាំងព្រះរាជបុត្រ
ពិសុទ្ធសោភា គង់គុជ្ជនទ្រា ហៃស្តេចចេញចរ ៗ
ឯព្រះកិលៀង ទាំង៤ទេទៀង ហៃ.ព្រះកូជ
ពលពាលខ្នានខ្នាប់ អឹងកាប់ខ្លួខ្លួរ កក្រេកអំព
បរិពតទិតនៅ ៗ ទាំងមហាប្រិថពី ផុលផងធូលី
ត្រលោមខ្លួលខ្ទៅ ស្អើទឹងស្រកស្រុត ទ្រោមទ្រុឌចុះទៅ
ដោយតេជះចោមចៅ ដៃដេតកផ្កា ៗ ស័ព្ទគង់ស័ព្ទស្គរ
អឹងកង់រំកិរ ក្រាស់ក្រៃគណនា ត្រៃសាំងគិរី
តទ្រិស្គរជ្វា ភ្លេងមនហិង្សា ភ្លេងសៀមសោតមាន ៗ
រីដង្ហែមុខ រៀបរៀងដល់ស្រុក សឹងហុនប្រធាន
ស្តេចទើបចេញចាក លះលាក់ព្រះលាន ដង្ហែក្រោយមាន
ប្រិទពន់ពេកក្រៃ ៗ ចង្អៀតមាគ៌ា ជ្រៀតជៃកពានពារ
តាមព្រះជៀសដៃ ប្រពូនប្រពាន ណាស់ណាន់ទាំងផ្លូវ
ក្រោមក្រមនោះនៃ ស្ញើក្កុកកស្យា ៗ មើលហើយគួរមើល

ព្រះអង្គប្រសើរ  តាំងបីអង្គ  ហាក់ទើបផ្ទោះផ្កាក់
ចុះចាកសួគ៌ា  មកស្ថិតនូវនា  ពពួកពលផង ៗ
ហាក់ព្រះអាទិត្យ  ឆៃទរិងរិទ្ធិ  បារមីកន្ទង
ឥតអង្គអង្គណា  ពាធាប៉ុនប៉ង  គួរគូស្មើផង
ព្រះអង្គឡើយណា ៗ  ក្សត្រតាំងប្រាំបី  រយហៃហចក្រ
លុះលាន់មាត់ថា  កញ្ញ័អើយកាពក្លក  កាពពេកមហិមា
មកយល់ចេស្ដា  ដៃដេត្តភូមី ៗ  ទោះបើទឹងស្ទាប់
ហៅមហាមានកត្ញ័  នូវនាលោកិយ៍  ឯអស់ជំនាង
ស្អិតស្អាងថ្មី ៗ  ហាក់ទេព្យកោសី  ផាន់ដៅរចនា ៗ
គន់ឯស្រះស្រង់  ទឹករងថ្លាយង់  កបនូវបុប្ផា
គួរឈរគួរឈប់  ដោយម្លប់ព្រឹក្សា  សម្រាកអាត្មា
បេះផលព្រឹក្សផង ៗ  ផម្ទុកពជា  ស្តែងស្ដេចលីលា
សន្ទឹមដោយផង  ទុកអស់ប្រដាប់  សម្រាប់នោះហោង
ស្ដេចស្ដែងកន្ទង  នឹងបុណ្យបុត្តក្សា ៗ  ហើយស្ដេចឲ្យដាក់
ចូលបតសំណាក់  នៃព្រះពន្លា  ឲ្យលៀងមន្ត្រី
សេនីសេនា  នូវក្សត្រប្រជា  បរិភោគភោជន៍ហៃ ៗ
ស្រទន់ល្ហបថ្ងៃ  ទទួលសង្គ័យ  ទើបព្រះភូមី
ស្តែងស្ដេចលីលា  យាត្រាចេញខ្វី  នានាំនាងស្រី
សច្ចាទុត្តម ៗ  នូវស្រីស្រីគ្គា  នារីបរិពារ

អកយាយចាស់ខ្ញុំ ហៃព្រះមហេសី ក្សត្រីសួគ៌សម
សៅដៃព្រះស្ងំ អនេកនានា ៗ ខ្ទះសើបខ្ទះលង់
និយាយដាវល្បែង អឹងកង់សោះសា ត្រេកសោមសប្បាយ
ពេះពយចិន្តា ពោលពាក្យបវរ ភ្លៀវភ្លាពេកក្រៃ ៗ
ស្ដេចត្រេបដោយផង ទតទីស្ថានផង រឹងពេញព្រះទ័យ
រៀង ៗ មាគ៌ា ថ្ងៃថ្ងាប្រែពៃ ព្រោងព្រាយត្រៃឈ
សុទ្ធសឹងបុប្ផា ៗ ស្ដេចបរក្រិត ពិតខែមួយស្អាត់
ដល់ចុងសេមា បញ្ឈប់រេហ៍ពល សុកលយោធា
ស្ដេចឡើងព្រះពន្លា បួលគង់ឥតហ្មង ៗ ស្ដេចប្រាំបីរយ
តាមហៃពីក្រោយ ខ្ទះដល់មកផង ខ្ទះនៅហោមន្ទ
សោកណុងស់ហោង មនុស្សប្រើនគិកកង ចង្អៀតមាគ៌ា ៗ
សល់គោដសល់លាន ទឹងដើរពុំបាន សឹងរង់ចាំគ្នា
ណៃនទាំងសឹងហុន ពេញពន់គាត់ណា ព្រះព្រៃពីក្សា
ល្អិតល្អោបវន្ទម ៗ ទើបព្រះចក្រី ត្រាស់ប្រើមន្ត្រី
អន្ទិឯកជាធំ ទៅទូលក្សត្រា យកក្សុទត្តម
យើងមកបន្តិ ដល់ដួចប្រាថ្នា ៗ កាលណោះអាមាត្យ
លុតលាព្រះបាទ ស្រួសកន់យាត្រា ដល់ក្រុងអាសុរិន
ធិបតិនយក្ស ដូចព្រះរាជា ស្ដេចផ្ដាំនោះហោង ៗ
ក្សិនក្រុងអាសុក ជ្រាបហើយក្សត្រា ស្ដេចផ្ដាំរិលស្ងួន

ទូត្ដើយអរក្ដាត់ ទឹងក្សត្រនេះម្ដង អាសូរបំណាង
បំណាចព្រួយប្រាណ ៗ ឥឡូវយើងចង់ ឲ្យស្ដេចបង្អង់
បន្តិចឲ្យបាន រិះរៀបទទួល ដោយគួរក្សត្រក្សាន្ត
លៀងអស់ទាហាន មន្ត្រីយោធា ៗ អាមាត្យបង្គំ
លាក្សត្រឧត្ដម វិលវឹងយាត្រា ទូលដោយកិច្ចចាំ
បណ្ដាំយក្សា ស្ដេចជ្រាបហើយណា ព្រមព្រះហឫទ័យ ៗ
ឯក្រុងអាសុក ស្ដេចប្រើសេនា ជាចូរវៃ ៗ
និមិត្តប្រដាប់ សម្រាបបុរី គ្រឿងទិព្វប្រពៃ
ជុំពលសេនា ៗ ការល្ហោះសេនីយ៍ បង្គំលាខ្ញី
ប្រាណប្រែកាឡា ទង់ជ័យស្វេតឆត្រ រាជរតិសុវណ្ណា
ចាជុំភាព ហោមហៅអាសុរី ៗ ចាំម៉ែរបាយមន់
ចាមរីសែនថ្វាន់ ក្មេងក្វាត់តន្ត្រី ផ្កាប្រាក់ផ្កាមាស
ឧកាសពិសី ផ្កាផ្កាស្ពួនស្រី សប្បាយអ៊ូអា ៗ
ហើយព្រះឥស្សូរ មានព្រះបន្ទូល បង្គាប់សេនា
ឲ្យតែងភោជន៍ខ្ញី បំណើរស្ពក៏ លៀងអស់យោធា
ទាហានពលផង ៗ បាយទឹកនូវស្រា ត្រីសាច់ញាំក្ងា
អន្ទង់បង្កង ទាំងជ្រូកទាំងមាន់ គ្រប់គ្រាន់ជាម្ដង
ខខ្ពស់ផង ឆ្អើតាំងរន្ទាល ៗ ស្ងួរប្រហើរ
ខ្ទះស្ងោរខ្ទះធ្វើ ណែកមនោះត្រកាល នំគមនំកង

គ្រពងនំនាល នំចាំងនំផាល អន្សមត្រាបផង ៗ
វីកសពីសី ថ្វាយតាំងប្រាំបី រយព្រះបរ្យះបរ្យង
មានសេទជា ពិសាក្ដាត់ហោង ក្សត្រក្សាន្តឥតគ្គង
សោយសព្វទេព ៗ ហើយព្រះកូមិន ហោមហៅអាសុរិន
យកគ្រឿងគន្ធា ពិគោឈ្មុយឈ្ងប់ អង្គអប់មាលា
ជូនទាន់ក្រិស្នា សម្រាប់ព្រះអង្គ ៗ នូវភជទជា
ទិព្វតន់ពិសា ពិសេះគួរគ្រង សោយកសកាជន៍មាស
ទកាសបញ្ចូន ហើយត្រាស់ឲ្យអង្គ អាមាត្យមួយណា ៗ
ទឹងនាំទៅថ្វាយ ក្សត្រថ្ងៃពន្រាយ ទាំងបីអង្គា
អាមាត្យបងចាំ បណ្តាំយក្សា ត្រេបគ្រង់យាត្រា
ដល់ព្រះទេវតី ៗ យក្សបត់បាតា ប្រណម្យទូលថា
បពិត្របក្រី ដ្យូតក្រុងអាសុរិន គូមិនយក្ខី
ប្រើយើងទ្វីទ្វី យកភជទុជា ៗ នូវគ្រឿងសុគន្ធ
ប្រសើរទិព្វតន់ ថ្វាយក្សត្រថ្ងៃថ្វា ធម្មិកស្ដេចស្ដាប់
សាសព្វ៌សេនា បើកបន្ទូលថា ហៃភជមន្ត្រី ៗ
ចូរវិលទៅទូល ក្សត្រថ្ងៃឥស្សូរ លើសលែងលោកិយ៍
អរណាស់នៅគុណ ពេកពុនឥតបី ថ្ងៃងថ្មីងមន្ត្រី
សព្វថ្ងៃនេះណា ៗ ព្រឹកនេះស្រោង ៗ អញនឹងយាសយាង
ទៅថ្វាយវន្ទា តាំងព្រះដៃដេត នូវនាងសច្ចា

មូលមួយទឹនគ្នា បង្គំក្សត្រថ្ងៃ ៗ អាមាត្យស្ដែនស្ដាប់
លាក់លាក្រឡាប់ ទៅទូលដៀសដៃ ដូចព្រះបណ្ដាំ
កិច្ចតាមនោះនៃ ជ្រាបក្នុងព្រះទ័យ ហើយបន្ទូលថា ៗ
ម្ដេចទៅមន្ត្រី យសស័ក្ដិសួស្ដី ទាហានអាសា
ពាជរត់ពាជី សេនីសេនា ពលពាលយោធា
ប្រែនតិចនេះម្ដង ៗ ចិត្តអញសន្ធិះ អល់ឯករើងរិះ
ថែរថបកន្ទង ខ្លាចពុំគួរគួ ត្រឹមត្រូវស្នួស្នង
ខ្លាសទេព្ដាផង គេទឹងនិន្ទា ៗ ប្រសិនយសគួច
ពុំស្មើពុំដូច ទឹងនាងទៀយណា បើអញទឹងឲ្យ
យល់ឆ្លាយមហិមា អាសូពុំឆា ស្មើថ្វើមហាទ័យ ៗ
អាមាត្យទូលថា បពិត្រព្រះមហា ក្សត្រគ្រានដៀសដៃ
ខ្ញុំមើលព្រះយស ខ្ពង់ខ្ពស់ប្រើងក្រៃ គួរគួស្មើដៃ
នូវនាងនិមល ៗ ក្សត្រយក្សធិបតី ព្ចពាក្យសេទី
ព្រះអង្គអរសល់ តែងទតអាមាត្យ សង្វាតខ្វាយខ្វល់
រៀបកេងមន្ទល់ ប្រាសាទសោភា ៗ លុះព្រឹកស្រាន់ស្រេច
កាល្មោះទើបស្ដេច ប្រើរាជសេនា ប្រជាប់គ្រប់ប្រាណ
យកយានថ្ងៃថ្លា គុជ្ជនអស្សពា រាជរតសារថី ៗ
ឲ្យនាំមីម្មា ទទួលរាជា ធម្មិកភូមី
ទៅដល់យក្ខថ្វាយ កកាយវន្ទី ទូលថាអាសុរី

ឥស្សូរសិរសា ៗ ប្រើខ្ញុំមកថ្កាន អញ្ជើញក្សត្រក្សាន
ទាំងបីអង្គា ស្តេចស្តាប់វាទី សេនីនោះណា
ព្រមព្រះទ័យា ប្រដាប់ព្រះអង្គ ៗ ទាំងនាងសុប្ចា
នូវរាជកុមារ ស្តេចពុំផ្សូផ្សង ទ្រង់ពរកសត្រា
លីលាឡើងគង់ លើយានវរមង្គ គលគាប់ប្រពៃ ៗ
បើកបាំងក្លស់ក្លុំ នូវកត្តិរម ចាកបរស្សវៃ
ព្រះស្នំស្រីអង្គា បរិពារសៅដៃ ពលផងក្រាស់ក្រៃ
ហែហាមក្សត្រា ៗ ស្តេចទតទីស្ថាន យល់ហាក់កិមាន
សម្តេចឥន្ទ្រា ប្រាសាទប្រសើរ មៀងមើលហើយណា
មិនផ្អែតនេត្រា ដល់ប៉ុនកេសី ៗ ដល់ហើយព្រះបាទ
ចុះចាកឃ្វាឃ្វាត យានយាសមុទី ទាំងនាងដេយ្យា
បុត្រក្សាតីសី លីលាះឡើងខ្ញី ប្រាសាទសុវណ្ណា ៗ
ហើយទើបស្តេចគង់ ទាំងបីព្រះអង្គ ថ្វាយវរវន្ទា
ក្សត្រយក្ខយង់យល់ ស្តេចដល់ហើយណា ត្រេកត្រាស់ស្នេហា
ជាទអរក្រៃ ៗ អរជ្ញីតទស្យា ចម្ងាយមាតា
ឆ្ងាយពន់វិសែ សេចក្តីស្នេហា បុត្តក្សាថ្មើមថ្ងៃ
ទអញគាប់ចៃ ចិត្តក្សត្រស្នេហា ៗ ហើយហាលថ្ងៃក្តៅ
ព្រះទ័យហ្វង់សៅ ព្រួយព្រាណរាជា លះលែងបុរី
ឆានីសេមា ទាំងពីរអង្គា លំបាកតិចអ្វី

ធម្មិកភជា　　សាសនាហា　　សូមទានចក្រ
ខ្ញុំមកពីនាយ　　សប្បាយអស់ក្តី　　ពុំមានក្រក្រិ
លំបាកឡើយណា ៗ　　ដោយផ្លូវពីឆ្ងាយ　　រូបរៀងដល់អាយ
សាន្តសុខមហិមា　　ចង់មកឲ្យដល់　　យុងយល់ក្សត្រា
ផ្ញើកផទិស្សា　　នូវល្អផ្ងលី ៗ　　ព្រះគុណមហាធ្ងន់
ទើបរស់រូបផន្ទ　　បិតបុណ្យភូមិ　　មេត្តាប្រោសប្រាណ
វិលថ្កានបុរី　　សូមផ្ញើជីវី　　នូវព្រះភជា ៗ
ឯនាងទេវី　　សច្ចាស្រស់ស្រី　　នាងឈ្ងៀងនេត្រា
ចង់មើលបុត្រ　　ប្រិមប្រិយសោភា　　ស្រីសុវណ្ណា
ពុំយល់ឡើយហោង ៗ　　គិតក្តង់ចិន្តា　　ទុំដូចអ្នកណា
អស់រូបកង់ផង　　ក្រមុំតូចទេ　　ឬសៅកែហោង
ចង់យល់បានម្តង　　សោះគិតសង្ការ ៗ　　នាងទុកទៅក្តង់
សំឡឹងយូរលង់　　ក្សត្រក្រុងអាសុភ　　ជីងដោយហឫទ័យ
ស្រីថ្ងៃនោះណា　　ចង់ឃើញធីតា　　ភជបុត្រស្នួស្នង ៗ
ស្តេចឲ្យក្សត្រិ　　អញ្ជើញទេវី　　ស្តេចចូលទៅហោង
កាន់បុត្រប្រិសា　　ថ្ងៃថ្នាតតហន្ធ　　នាងយាងដល់ផ្គង
ទតយល់ធីតា ៗ　　ភ្លឺផ្ទេកទភាស　　រឿងលេចដូចមាស
នុព្វគុណហោងណា　　ហាក់បុណ្ណមីច័ន្ទ្រ　　វែងស្ពានវិហាស៍
ព្រះកត្រូដ៏ះថ្នា　　ល្អល្អះប្រិមប្រិ ៗ　　នាងគង់មិម្នា

ព្រះហស្តប្រាប់ ឧបអង្គបុត្រី ថើបថ្ពៃត្រកិត
ថ្ងួញជិតអង្គស្រី គៀកកើយបេតី លួងលោមបរបារ ៗ
កាណ្លោះសោតហោង ស្រីស្រស់ឥតធ្គង នាងសុវណ្ណា
នាងខ្មាសអៀនឱន ស្រពោនកក្ត្រា លើកកវន្ទា
សម្តេចជីនី ៗ ដាក់មុខលំញង ពុំចេញសូរសៀង
ស្ងៀមស្ងាត់ទូរទី កាណ្លោះមាតា សច្ចាទេវី
ចង់ស្ដាប់សំដី រាជបុត្របរិសារ ៗ បបកព្រលឹង
មាសសើយនាងខឹង ទឹងព្រះមាតា ប្ដូមួយមេខ្មាស
ណាមាសពុំអា ពុំចេញបរបារ ទឹងម្ដាយឡើយហោង ៗ
ម្ដាយសោតសឹងស្រី អៀនអន់ខ្មាសអ៊ី អក្កមាសឥតធ្គង
ចូរបើកទិស្សា ស្ពក៉សូសង ទឹងម្ដាយទះម្ដង
ឲ្យធូរចិន្តា ៗ បំប៉ាសុវណ្ណ ឆ្លើយស្នងរឹងថ្កាន
ទឹងនាងសច្ចា ខ្ញុំឥតបើខ្មាស ឱកាសឡើយណា
ដោយពុំធ្លាប់ជា ខ្ញុំព្រះជីនី ៗ នាងទូលបណ្ដោះ
បំប៉ារុសចុះ ចាកទិសក្សត្រីយ៍ ដោយដូចអ្នកអប់
ត្រឡប់ទាំងទី ប្រាសាទសោភី សាយសព្វសោះសា ៗ
ឯព្រះជីនី ស្ដេចស្ដាប់សំដី បុត្រត្អូញពុំអារ
ទតទាំងព្រះទន្ត សោកទរូមហា ខិលនៅទិស្សា
ប្រកិតរៀងកាយ ៗ ហើយយល់បំប៉ា ជ្រុសពីទិស្សា

ខ្ញុំនៃក្លូបខ្វរខ្វាយ　រឹងពេញចិត្តដាក់　ថាអ្នកមាសម្ដាយ
ល្អមេត្តបអម្បាយ　គ្រប់លក្ខណា ។　មើលមិនមានគ្គន
ចិត្តម្ដាយទៀយហោង　ដល់ប៉ុនកេសា　ហៃស្ងួនគោមផ្ទៅ
អ្នកនៅនេះណា　ម្ដាយអ្នកទឹងលា　វិលរឹងទៅថ្កាន ។
ហើយនាងស្រីរត្ន　លីហៅវិលថ្វាត់　មូលមួយក្សត្រក្សាន្ត
នាងទូលស្វាមី　ទេពប្រធាន　ពីបុត្រកល្យាណ
ឥតខ្វះទៀយណា ។　ក្សណ្ណាះក្សត្រយក្ខ　ស្តេចប្រែព្រះភ័ក្ត្រ
ត្រាស់ដណ្ដឹងថា　ហៃរក្សត្រិ　នាងស្រីសច្ចា
ឃើញបុត្រប្រសារ　ដាក់ប្ដូនៅទៀយ ។　គួរគូស្នេហា
នឹងរាជឱស្សា　ប្ដូមេត្តបនាងងើយ　ទើបនាងសច្ចា
វន្ទាទូលថ្លើយ　ស្នងក្សត្រគ្រានត្រើយ　ឥស្សូរយក្សៈ ។
សូមទានខ្ញុំយល់　បុត្ររត្ននិមល　ទ្រើសទ្រង់លក្ខណា
ឯកឯងត្រឹមត្រូវ　គួរគូនៅជា　ផ្ទើមក្ដុងកាក
ហេមន្តបុរី ។　គន់ទៅអស់អគ្គ　ល្អល្អះត្រួបង់
ដូចបន្ទូបណាមី　មិនមានហៅគ្គង　ប៉ុនល្អងគួលី
គួរគាប់ជាតី　រាជវង្សពង្សា ។　ស្តេចស្ដាប់នាងថ្លែង
ញញឹមអរឯង　ឥតឯកុបមា　រឹងពេញព្រះទ័យ
ក្សត្រថ្លៃក្ដាត់ណា　នឹងបុត្រពុំអារ　បន្ទូលស្នេស្នង ។
ធម្មិកក្ដូមី　លើកកវន្ទី　សំណោះថ្លើយថ្លង

សូមទានបើទៅ យូរទៅហើយហោង ក្នកនគរផង
លំបាកមហិមា ៗ ហេតុនោះនេះម្ដង សូមព្រះប្រោះប្រង
ទ្រង់ព្រះករុណា បង់សូមរន្ធាប់ ការឆាប់ម្នីម្នា
ទឹងអាលក្រាបលា ត្រឡប់វិលវិ ៗ កាឈ្មោះយក្សា
ស្ដាប់ព្រះអនុជា ទូលទើបក្សត្រថ្វី ស្ដេចត្រាស់ឲ្យហៅ
ហោមកហើយនៃ បន្ទូលថាហៃ អស់ពងហោព ៗ
បូរមើលបុក្សពា សំពង្សវេលា ផាត់នូវអន្ទ្រា
សំណុំពង្សនាគ តើនូវត្រង់ណា ទឹងស្រឡាញ់គ្នា
ប្តូរទេនេះម្ដង ៗ បេកមាសពេលា ពេគបុក្សធាយា
លក្ខិណោទីផង មើលឲ្យទេទៀង កុំស្មៀងប៉ុនស្អង
អាសូរក្ដាត់ហោង ជ្រិតកូនកំព្រា ៗ ហោស្ដាប់ព្រះសូរ
ស្រេចហើយហោតូរ ដោយជួងជតា ឃើញជាក់ហើយថ្វាយ
រំសាយទូលថា ល្អគ្រប់លក្ខិណា គប់នូវសម្បត្តិ ៗ
យើនយូរទឹងគ្នា កើតយសសក្ខិតា បុណ្យបារមីក្ដាត់
កេរ្យមអស់អាណា ប្រជាពស្ដ្ររដ្ឋ ទាំងបីមហាក្សត្រ
បានពឹងបុត្រភ្ងា ៗ បពិត្របក្រើ បេកមាសនោះក្ដី
សុីងបើកដូបគ្នា ទាំងឆ្នាំទាំងខែ ឥតឯសក្ការ
មានទាំងពិលា ជាន់ឆាយនោះហោង ៗ ក្សត្របីអគ្គា
ស្ដាប់ពាក្យហោព ស្ដេចអរកន្ទង ស្ដេចឲ្យបញ្ជី

ពាពីលាផង  ស្រាប់ស្រេចហើយហោង  ទើបក្រុងអាសុក ៗ
បើកបន្ទូលស្នង  ឥឡូវនេះមួង  យើងយកស្ពានណា
និងយកពេជ្ររតន៍  តូបក្តាត់ណាស់ណា  ចូលមហាក្សត្រា
ឲ្យសង់ទៀតខ្ញី ៗ  របនាធ្លាក់ធ្លក់  ក្រូចក្លាយត្របក
កែមកាលមុទី  កែវព្រះពាទពេជ្រ  លាយលេចផាក្បី
សូវណ្ណពំងសី  នៃបនិតបុសា ៗ  ធម្មិកក្បូបាល
ទទួលទិក្ខា  ថ្វាយបង្គំលា  ទាំងបីព្រះអង្គ
ក្រេបត្រង់យាត្រា  ដល់ព្រះពន្លា  ស្តេចបរបូលផ្គង ៗ
ព្រួយព្រះបិត្តា  ដ្បិតព្រះវេលា  សោតជិតហើយហោង
ទ្រង់វែងថែមថប  ថៃថយកន្ទង  កាលណោះសោតហោង
ក្តៅដល់អាស្នា ៗ  សម្តេចកោសី  បើកទិព្វចក្ខុ
ដឹងដោយប្រាជ្ញា  ស្តេចចុះជាកស្ពាន  ក៏មានត្រិង្សា
ដល់ដែនកស្យបា  សង់ពេនពិធី ៗ  ធាធំទូលាយ
សុវណ្ណព្រោងព្រាយ  កែមកែវមណី  ក្បីផ្ទុកប្រាក់
ភ្លៀលធ្លាត់សីងមណី  រុំយោលសឹងក្បី  មាសមាលមាលា ៗ
ចងពិដានផាស  គ្រប់ពណ៌ពេញពាស  ប៉ានប៉ាក់របនា
សែសយលុះលេច  ក្បូរក្បាច់សោភា  រូបម្ករពាំផ្កា
លេងលើផ្លូវសែ ៗ  មានទាំងពិទួង  ហើបហែលត្រសង
ហិចហក់វិលវៃ  ផ្កាប់ខាងលើលោ  ក្រៀបត្រាក្រាសក្រែ

រូបរស់វិសេស　អស់អគ្គរូបា ៗ　វិគ្រែទីនាំង
វិចិត្របិទបាំង　ព្រះសន្ធិយា　កុម្ភណ្ឌនូវគ្រុឌ
លុះលុតបាទា　ទ្រវែត្រែក្រឡា　ទីនាំងនោះហោង ៗ
សឹងមានសន្ទុព្វគុណ　ឆ្អិនឆ្អៅសោភ័ន　ធ្ងុះធ្ងុះកន្ទង
វីដណ្ដីរគាប់　ក្បូរក្បាច់ចាំងសង　ព្រះក្រាសសោភហោង
មរកតស្វស្ដី ៗ　គាល្មោះសេនា　យល់ហើយយាត្រា
ទៅទូលចក្រី　ស្ដេចជ្រាបហើយអរ　ប្រសើរឥតបី
រីងវៃស្សន៍បារមី　បុត្រថ្ងៃពិសា ៗ　លុះទៀបសន្ទត់
ទឹងដល់កំណត់　បុក្សពាពិលា　ឯអគ្គក្សត្រថ្ងៃ
ព្រួយព្រះទ័យក្រា　ព្រះរាជបុត្រា　ឥតអ៊ីទីងទ្រង់ ៗ
ស្ដេចផ្សង់បារមី　បុត្ររតន៍ពីសី　ពីសុទ្ធវរវង្ស
សូមអស់ទេព្ដា　ជួយទនុកបម្រុង　និមិត្តគ្រឿងទ្រង់
ដូចខ្ញុំប្រាថ្នា ៗ　ពេលនោះក្ដៅដល់　ត្រែត្រឹងរមនួល
សម្ដេចឥន្ទ្រា　ហៀវហោះផ្លោះផ្លូក　សឹងទេពទេវា
នាំគ្រឿងសោភា　ចរចុះមកថ្វាយ ៗ　ទឹកទិព្វសឹងអប់
យកមកស្រោចស្រព　ដៃជេតពន្លាយ　គ្រឿងសុគន្ធា
ទេវតាំងឡាយ　ឈាយលាបព្រះកាយ　ព្រះរាជកុមារ ៗ

## អេះបទពំនោល

លុះព្រឹកស្រាងស្រេចសុរិយា　ដៃជេតរាជា

ប្រដាប់ព្រះអគ្គីចក្រ ទ្រង់ព្រះមកុដពេជ្រកែវមណី
ធ្វាសធ្នូរស្មី ពន្លឺភ្លឺផ្លេកព្រោងព្រាយ ៗ
សម្តេចនរិន្ទឥន្ទ្រា កងរត់នាំពា
ព្រះមាតុលីបុត្របើកបរ ព្រះបាទធម្មិកកូនរ
គង់រត់ស្តេចបរ អណ្តែតអណ្តោយនូវគ្នា ៗ
ទាំងព្រហ្មបរិវារយក្សត្រា សឹងគង់រថា
ហែហមព្រះបាទចក្រី ព្រះកិលៀនទាំង ៤ ក្តី
រៀបអស់មន្ត្រី កំណត់កំណាន់គ្រប់គ្នា ៗ
មានទព័ពាះជីគុជ្ជា ជិះបរយាត្រា
ដង្ហែសង្ខាំងភ្លេងស្គាំ អាប់អស់មេឃម៍ស្រទំ
ដោយទេព្តានាំ ប៉ុនបិទអាកាសវេហាស៍ ៗ
ផាវខែលកាំភ្លើងធ្នូសារ ទូនទាំងដេយ្យា
ដើរដោយសក្កាត់គួរស្បែង បំប៉ែសំសែទូវលំពែង
កាំភ្លើងផេះឯង ប្រគត់ប្រគាន់ដោយដៃ ៗ
គាតគង់ខ្ទុយប៊ុស្រលៃ សាប់សូគង់ដៃ
កក្រិកអំពើកកស្យេងា ៗ សំកោហូទុកស្គារ
ពាតមោងស្គគ្ងា ប៊ីអរទូរទ្រអឺងអាប់ ៗ
ចាប៊ីត្រែស័ង្ខស្គទព័ រនាទកូនក្រាប់
អគ្គួចសែរដៀវទៀវញ ៗ ហែមកក្រឿនៗ ផ្លូវគ្នា

ក្សត្រក្សាន្តទ្រង់ធម៌ រង់រឿងកណ្ដាលពលផង ។
ស្ដេចដល់មណ្ឌលហើយហោង អ្នកទ្វារចាំងសង
បិទជិតមិនឲ្យចូលបាន គឹមលៃស្រីថ្ងៃកល្យាណ
យកទ្រព្យប្រទាន អ្នកទ្វារទឹងអាលយាត្រា ។
បង្អង់លុងលុះឡើយណា ក្រែងខុសពិលា
នូវពានទៅលើកាលខៃ អ្នកទ្វារអរឯងពេកក្រៃ
បើកទ្វារវៃ ៗ អញ្ជើញព្រះអង្គចូលឋាន ។
ស្ដេចឡើងទៅគង់មួយស្ថាន បន្ទាការមាន
រៀបរៀងជាផ្លូវសោះសា ។

# នេះបទកាកគតិ

ក្សត្រយក្ខធិបតី បើកបន្ទូលថ្វី សំណោះស្នេស្នង
សុរិយាកុមារ ត្រកាលនេះម្ដង ទៅអញ្ជើញផង
ឲ្យចូលមកណា ។ សុរិយាឮហើយ តាំងនៅកន្ទើយ
ប្រដាប់អាត្មា ចេញមកទទួល ដៃដេគភជា
អញ្ជើញយាត្រា ចូលស្ថានពិធី ។ ស្ដេចដោះព្រះទម្រង់
ពីព្រះហស្តទ្រង់ រីកេកំងសី ឲ្យទៅសុរិយា
កុមារធិបតី កម្ពុបុរី ទតរម្យហោង ។
ទើបព្រះកោសី នាំស្ដេចចូលថ្វី ក្នុងគង់ឥតហ្លួង
ស្ដេចទាំងប្រាំបី វេយក្ដីសោតហោង ហៅចូលមកផង

រៀបរៀងនូវគ្នា ។ ខាន់ស្លាបាយសី ចូលជើងនូវទី
ជុំនុំនោះណា កុដង្គនាគី នាងស្រីវិទ្យា
ទទួលខាន់ស្លា កាលណោះឯងះហោង ។ ឯសុវណ្ណា
គិតដល់មាតា បិតាសួនគ្រង ជាទីអនិច្ចា
កំព្រាកន្ទួង ឥតញាតិផៅផង ជាពីរឡើយណា ។
នាងទ្រង់ព្រះកន្សែង សោយសោកកន្ទួង ជោជល់ឆាក
រឹងគិតរឹងខ្មាស អស់កស្ត្រប្រជា នូវអង្គសេនា
មុខមន្ត្រីផង ។ រីគាល្ហោះណា នាងស្រីសុច្ចតា
វររត្នប្រុះប្រុង ទាំងនាងបិត្រា សោកាសោតហោង
នាងមន្ទាផង នូវទេព្វកញ្ញា ។ សោតសឹងបេត្រី
នាំរាជសេទី ចុះចាកស្ងួតា មួលមកជួយការ
អាពាហ៍ពិពាហ៍ យល់នាងគិតា សោយសោកកន្ទួង ។
នាងស្រីសុច្ចតា ល្ងង់ណោមឃាត់ថា នាងអើយនេះម្តង
កុំមាសឧត្តម នាងយំឡើយហោង ទោសទេព្យមនុស្សផង
សឹងជូប្រោះណា ។ បើគ្មានជំនុក ជនីជាក់ទុក
មានក្រុងអាសុក ហើយមានទាំងយើង នូវអស់ទេវតា
ទីងខ្ពស់នរណា ក្រែកទឹងយើងហោង ។ ក្សែណ្ណារសុវណ្ណា
ស្រស់ព្រះភ័ក្ត្រា សោយសោកផង ទើបអស់ទេព្តា
ថ្លៃថ្លាឥតហ្មង យកទឹកទិពផង ជំរះអង្គា ។

ស្រេចហើយស្រីតន់ នាងទ្រង់សុគន្ធ លាយលាបកាយា
ស្រីទេពអប្សរ បវរធីតា បំពាក់គ្រឿងជា
មិនឲ្យមានហ្មង ៗ នាងទ្រង់ព្រះពស្ត្រ ប្រពៃស្រៀវស្រស់
សោតសំគន្ធ ហើយដន្ដប់ស្បៃ កោសេយ្យកស្ត្រផង
លឿងលែមបំព្រង ផ្លូវផង់ខាត់ណា ៗ រត់កែវកងករ
នូវធ្មឹមអំព កន្ទល់ទិញ្យ សង្វាហូរាក
រន្ទាលមហិមា ល្អលើសទេព្ដា ស្ពានស្ទូតិសោតហោង ៗ
លុះបានពិលា នាងស្រីបវិត្រា នាងនាំចេញផ្គង
ស្រីទេពកញ្ញា ទេព្ដានោះផង យកងហៃត្រសង
ណាស់ណាន់ត្រៀបត្រា ៗ កាល្មោះព្រះព្រហ្ម ទ្រង់ឆត្រជ័យធំ
បើកបាំងធិតា ត្រៃស័គ្គទេន្ទ្រ គ្រប់ភ្ញូងមហិមា
អស់អគ្គយក្សា បាចបាញ់កាំភ្លើង ៗ សាប់ស្នូរសន្ធឹក
លាន់ឮពន្ទឹក ដោយតេជៈបក្ដល់ផ្ដើង រូហានរន្ទាល
ខ្ញៀវខ្ញូរឮឡើង សឹងសព្ទកាំភ្លើង វៃផ្សងផ្សប់វហាស៍ ៗ
ហាក់ដូចក្រឡាប់ សឹងហុនស្មើផ្កាប់ ផ្អៀងផែនកស្សជា
ញាប់ញ័របរិពន្ធ រន្ធត់សោះសារ ព្រៃព្រឹក្សនានា
ស្វាកស្វុករុះរោយ ៗ អម្រឹតបក្សា កិតកៃតកមា
រត់មិនមើលក្រោយ សៀតសឹកលាក់ខ្លួន ពឹងពួនមិនឲ្យ
ឮឡើយផ្សាដោយ ជាសត្វនោះណា ៗ បិត្រាទេវី

នាំនាងដល់ទី ពេងរត់សោកា ឲ្យនាងគង់ត្រឹម
ផ្ទឹមនឹងពជា គួរគូស្នេហា ឯកឥតពីរផង ។
ក្សត្រយក្ខធិបតី ធម្មិកភូមី គង់ផ្ទឹមជាម្ដង
ស្ដេចឲ្យជញ្ជូន មាសប្រាក់កែវកង តរលប់ត្នោតហោង
ដោយគួរទីទៃ ។ លុះដល់ពេលា សម្ដេចឥន្ទ្រា
អុចទៀនមាសមៃ បានបុក្សនាយា ហើយណាក្សត្រថ្ងៃ
បិតបាយសីវៃ កាលណោះឯងណា ។ ហើយមានពពិល
មាសមៃស្រស់ស្រិល បិតទៀនដូចផ្កា បង្វិលប្រាំបួន
ជន្ទប់ជុំជា សូរេចហើយណា ទើបព្រះកោសី ។
ជណ្ដឹងក្សត្រា ដើមការទ្វេហា ស្ដេចបានទ្រព្យអ្វី
ចងដៃកជបុត្រ ពិសុទ្ធក្សាប្រើ ប្រាប់មកយើងខ្ញុំ
ឥឡូវនេះណា ។ យក្ខយនឹងប្រធាន ត្លាស់ផ្ញើយសង់សាន
សម្ដេចឥន្ទ្រា ទ្រព្យខ្ពស់បុងត្នោត ខ្ញុំសោតឲ្យជា
ចំណងហត្ថា បុត្ររត្នពីរពង្ស ។ ទោះស្ងូត្រច័ត្រ
កជរត់សម្បត្តិ ខ្ញុំព្រះអង្គហោង ខ្ញុំសោតលើកឲ្យ
សែបសោយកជក្សី នគរយក្ខយង់ សឹងហ៊ុននេះណា ។
ធម្មិកភូមី ផ្ញើយផ្គងកោសី ហោមហៅទៅ
ទ្រព្យគាំងនេះទៃ ចងដៃបុត្តក្សា កែជសេមា
ហោមន្ត្រស្រុកនាយ ។ ខ្ញុំសោតប្រគល់ ឲ្យកូនទិមល

តាំងពីព្រេនាយ　គ្រប់គ្រងសេនា　ប្រជាទាំងឡាយ
យើងឪពុកម្តាយ　បាស់ហើយនេះម្តង ៗ　សម្តេចកោសី
ជ្រាបអស់សំដី　ក្សត្រក្សានទាំងសង　ស្តេចស្រែកឃោសនា
ទេព្តានោះផង　ស្តាប់ហើយអ្នកគោង　ជួយជាសាក្សី ៗ
ហើយឲ្យកុមារ　នូវពជធិតា　ក្រញូក្រាបវន្ទី
ពីរពង្សក្សត្រា　នូវព្រះជីនី　ស្តេចឲ្យពពី
សេមសុខសូសល់ ៗ　ឲ្យយឺននូវគ្នា　បម្រើនជណ្ណសា
បុត្ររតន៍និមល　បៀសបាកពោគ្គា　ផរាជិតជល់
អំពើរអំពល់　គូវគុំបីមាន ៗ　ពប្នះអស់សត្រូវ
មារមុះទូទៅ　បាលវាញ់សត្វស្ពាន　បំបាក់បំបប
វ៉ែប្រែបប្រួញប្រាណ　ពុំឃើសឃ្លងបាន　បៀតបៀនឡើយណា ៗ
សប់ប្រទេសផង　មូលមកអឹងកង　ថ្វាយកវន្ទា
ថ្កល់ថ្កើងយឺនយស　ខ្ពង់ខ្ពស់សក្ខិតា　ក្រេមក្សាន្តប្រជា
ពស្ត្ររដ្ឋសត្វថាន ៗ　កាល្មោះសោតណោ　អស់អង្គក្សត្រា
ទីទៃគ្រប់ប្រាណ　គន់ព្រះលក្ខិណា　ធិតាកល្យាណ
នូវព្រះប្រធាន　ដៃដេតកាជា ៗ　គន់ហើយរឹតគន់
មិនមានផ្អែតផ្អន់　ដល់ជាក់នេត្រា　ទោះទាំងមន្ត្រី
សេនីសេនា　នូវក្រស្ត្រប្រជា　មកមីប្រុះផ្ទៀត ៗ
ដណ្តើមពានពា　ណាស់ណាន់ដៃផង្គា　ខំខិតបែបៀត

ពាពិតទ្រេតទ្រោត  លោលោតសឹកសៀត  អើតហើយអើតទៀត
មើលទៅពីឆ្ងាយ ៗ  ទាំងចាស់ខ្ចង់កោង  សក់សោតសរព្រោង
ដោះសោតសន្ទាយ  ធ្មេញបាក់គ្រហុប  ទ្រទ្រុបពីឆ្ងាយ
ក្រមុំមេម៉ាយ  មើលមីមហិមា ៗ  ពរចៅពរកូន
ប្រពានប្រពូន  ផ្តួលដេកលើគ្នា  មិនទៅផ្ទះសាយ
អត់បាយអត់ស្ងា  ភ្លេចភ្លាំងអាត្មា  ពោយរឹងឈរនៅ ៗ
សត្តុសរសើរគង់  ទ្រហឹងរំពង  បានយល់ព្រះចៅ
ស្មើបានសម្បត្តិ  សួរថ្កាត់ហើយហៅ  ជីតាចៅពៅ
អាចឲ្យបានយល់  ល្អហើយល្អពេក  ទាំងគូឯងឯក
ឥតអ្នកណាដល់  ទោះទាំងទេព្តា  នូវនាមខ្ពល់
សួរសឹងឆ្ងាយសល់  តុំស្មើរទៀយណា ៗ  ឯវិទនូវខ្វាក់
កំពុកកំបាក់  ចឹងខានយាត្រា  ជាទិះទិកម្ម
ចងចាំវេក  ព្យាធិពេតា  បៀតបៀនក្តាត់ហោង
គេទៅនោៗ  ឯងនៅប្រលើ  បាបអ្វីនេះម្តង
គិតហើយគួរស្លាប់  គួរតាប់កន្ទង់  គេមើលគង់ៗ  ឯងទៅពុំបាន ៗ
ស្រែបទើបព្រះឥន្ទ  ចោមចៅនរិន  អញ្ជើញក្សត្រក្សាន
ចរចូលប្រាសាទ  ស្អាងស្អាតទិព្វស្ថាន  ទាំងនាថគលព្រាណ
សួរបទហើយណា ៗ  ហើយព្រះកោសី.  លាក់លាវិធី
ស្ថានត្រៃត្រឹងព្រា  ទោះទាំងនាងនាថ  ស្រីសុច្ចតា  នូវទេពទេព

សឹងវិលវិលហោង ៗ ក្សិណក្សត្រអាសុរី ធម្មិកភូមី

ឲ្យភ្នាក់ងារផង លើកដាក់ស្តុកស្បៀង ឲ្យលៀងភ្ញៀវផង

មុខមន្ត្រីកង បរិភោគគ្រប់គ្នា ៗ លើកក្រយាស្ងោយ

ភាជន៍មាសមកឲ្យ អស់អង្គក្សត្រា តាំងនាយរេហ៍ពល

ស្កប់ស្កល់កោក្តា ស៊ីបាយផឹកស្រា សូរេបហើយនៃ ៗ

ធម្មិករាជា នូវនាងសច្ចា ត្រឡប់វិលវិ

គង់ព្រះពន្លា ថ្ងៃថ្ងាប្រពៃ ក្សេមក្សាន្តព្រះទ័យ

សម្តេចរាជា ៗ ដៃដេតភូមី ស្នាលស្និតមេត្រី

នាងសុវណ្ណា លុងតិចព្រះបាទ ននាដក្សត្រា

នូវនាងសច្ចា ព្រះវរជិនី ៗ ស្តេចឡើងទៅគាល់

ក្សត្រថ្ងៃទ្រង់ធម៌ ហោមហៅអាសុរី ប្រញ្ញាប្រាណាបង្គំ

ប្រណម្យវន្ទី ទើបទូលទៅទ្វី នូវពាក្យស្នេហា ៗ

បពិត្រក្រាបទូល ព្រះអង្គឥស្សូរ សូមជ្រាបចិន្តា

ដ្បិតមកនេះលុង ព្រោះបង់សោមា នូវពស្ត្រប្រជា

យូរពេកហើយហោង ៗ ឥឡូវនេះណា ខ្ញុំសូមក្រាបលា

ត្រឡប់វិលផង ក្រែងអស់អាណា ប្រជារាស្ត្រផង

មានកើតសៅហ្មង ក្រោយខ្ញុំយាត្រា ៗ តាឈ្មោះក្សត្រយក្ខ

ស្តេងស្តេចស្តាប់ជាក់ បន្ទូលត្រាស់ថា ប្អូនអើយចូលនៅ

អាលទៅអ៊ីណា អាសូរកុមារ រាជបុត្រស្នែងស្នង ៗ

អ្នកទឹងអាឡៃ    ក្រៀបក្រំព្រះទ័យ    សោយសោកសៅហ្មង
សង្រេងក្រោយក្រៃ    នៅនៃអញបង    ឃាត់ប្អូនករុណាហោង
កុំអាលយាត្រា ៗ    ធម្មិកប្រះប្រង    ទូលទៅរឹងស្នង
ព្រះរៀមកជា    ខ្ញុំសោកពុំបង់    ព្រោះបង់ឃ្លាតឃ្លា
ខ្ញុំព្រះបាទា    ចិត្តបង់នៅកាយ ៗ    តែខ្ញុំថប់សល់
ភយរង្គមទូល    ហោមន្តឯនាយ    បើអត់ពីខ្ញុំ
ចាកចំបែងឆ្ងាយ    សំពុំសប្បាយ    ដូចនៅសព្វគ្រា ៗ
ហេតុនេះទើបខ្ញុំ    លាព្រះឧត្តម    គេចត្រង់សមា
សូមផ្ញើឱរស    ប្រាណប្រុសនៅជា    ខ្ញុំព្រះបាទា
ហោមហៅអាសុរី ៗ    រីព្រះកិលៀង    តាំង ២ ទេទៀង
នូវមុខមន្ត្រី    សោកសឹងទុកនៅ    ចាំហៅក្លាប្រឹ
បុត្ររតនពិសី    នូវកាយនេះណា ៗ    ទោះខុសទោះត្គង
សូមព្រះប្រះប្រង    ទ្រង់ព្រះមេត្តា    គាបអនុកូល
អាសូករុណា    ស្មើបុត្រខទក    ពិតពុំសង្ស ៗ
វីក្សត្រយក្ខយង់    សម្ពះសាសនី    កុំព្រួយព្រះទ័យ
ហេតុដ្បិតស្រឡាញ់    ពិតពេញចិត្តក្រៃ    អគ្គីសំក្ស័យ
កាលមុនមិញណា ៗ    ចិត្តបងសព្វថ្ងៃ    ទុកស្មើស្រីថ្ងៃ
នាងសុវណ្ណា    ហេតុនោះទើបឲ្យ    តាមដោយប្រាថ្នា
ខុសគាប់គាបជា    នោះនៅស្មើបង ៗ    សង្កាតទុកដាក់

បុត្រីវល័ក្ស    អាសូរគ្នាត់ហោង    ម្តេចឲ្យអាសា
ឥតការនេះម្តង    សំណើចអ្នកផង    លោកទឹងទិន្ទា ៗ
កុំក្សត្រឧត្តម    ថែថបបុប្ផារម្មណ៍    បងទឹងជានា
តោះតាំងមន្ទីរ    សេនីយោធា    នូវ ៤ ក្សត្រា
ព្រះតិលៀងថ្ងៃ ៗ    បើស្តេចទឹងទៅ    ស្រុកទេសលំនៅ
នគរនាយនៃ    មិនហ៊ានឃាត់ណាស់    ក្រែងពាស់ព្រះទ័យ
ទុះបានអាឡៃ    មិនបង់ឃ្លាតឃ្លា ៗ    ធម្មិកកុម្មី
ស្តេចស្តាប់យកទ្ទី    ព្រមព្រះបិត្តា    ទុនទុបកជបុត្រ
ពិស្ទុះស្នេហា    បន្ទូលផ្តាំថា    ហៃសួនឧត្តម ៗ
ឆ្ងាយទឹងបិតា    ចរចេញយាត្រា    លាកលះលែងលំ
នូវទឹងក្រឡាប់    រិលធាប់ចាកចំ    បែងបង់កូនកុំ
ក្តួចពាក្យបិតា ៗ    កុំបាដ់អឹង    ទាស់ទែងទទឹង
ព្រះអគ្គកជា    គាល់ហៀផ្តាប់ផ្គុន    អស់អញទុស្សា
សព្វទិនទេវ    ប្រែសព្រាណប្រែក្រតី ៗ    មួយសុវណ្ណា
ខុសគាប់ក្តីណា    កុំកូនពិសី    ពោលពាក្យបោកបោះ
ទ្រគោះសំដី    ក្រេវក្រោធខ្ពលទ្ធិ    ឲ្យអាក់បិន្ទា ៗ
កូនើយបូរង្ស៊ី    ខ្លួនសួននេះលើ    លើលោកករុណា
កុំបាប្រែខ្លួស    រង់រូសចរចា    ពុំគោតអ្នកជា
បាក្រុកឡើយនៃ ៗ    បូរពេះដាក់ខ្លួន    គួរគិតក្តីស្នួន

តាមព្រះហឫទ័យ　កុំហ៊ានពន់ពេក　លើសពន់វិសេស
កុំខ្លាចពេកក្រៃ　ក្រៅក្រិត្យក្សត្រា ។　ឯព្រះជនី
ថ្នាក់ថ្នមបេត្តី　រាជបុត្រប្រសារ　បះបោសបំពេល
អន្ទែលអង្គា　ថើបថៃផ្តាំថា　ហៃមាសពន្លាយ ។
នួណា នាងណា　យើងពីរនឹងណា　ទៅទីស្ថានឆ្ងាយ
ផ្ញើតែរាជបុត្រ　ពិសុត្តធោមធាយ　នឹងនាងនូវអាយ
រួមភក់ស្នេហា ។　កាណោះទេវី　ប្រសើរស្រស់ស្រី
នាងសុវណ្ណា　គ្រញូក្រាបផ្គុំ　ប្រណម្យវន្ទា
ពីព្រះភក្ដា　ផ្ចូញជិតធ្ងូលី ។　នាងនាដស្រីថ្លៃ
គន់គិតអាឡៃ　ព្រះវរជនី　នាងទូលផ្តេកផ្តិត
ស្នាលស្និតមេត្រី　ឱម្ចាស់អង្គឥត　សូរខ្ញុំនេះណា ។
ពីដូចខ្ញុំបាន　ក្សត្រថ្លៃប្រធាន　ជាមកុដសិរសា
ពុំដែលឲ្យអាក់　ថ្នាំងថ្នាក់ចិន្តា　ឥឡូវឃ្លាតឃ្លា
ឆ្ងាយនេះជាម្តង ។　ខ្ញុំរងចប់សល់　បាបអ្វីមកផ្តល់
ព្រាត់ព្រះបង្រះបង្រង　ខ្ញុំប៉ង់នឹងផ្ញើ　ខ្ញុំនលើអ្នកហោង
ម្ដេចស្ដេចរំលងផ្គង　ឲ្យខ្ញុំកំព្រា　ខ្ញុំព្រាត់ពីស្រុក
ពីព្រះជនក　ដីទីឆ្ងាយណា　មកបានព្រះអង្គ
ទ្រើសទ្រង់មេត្តា　ឥឡូវនេះឃ្លា　ឃ្លាតចាកចេញទៅ ។
រីនាងសច្ចា　ស្តាប់បុត្រប្រសារ　ទូលទុក្ខកាត់ក្តៅ

នាងលួងលោមថា ពុំងាស្រែពៅ កូនអើយម្តាយនៅ
ត្រងត្រុងភាព ៗ ឆាប់ទៅមិនយូរ ម្តាយសោកអាសូ
នាងនៅកំព្រា កុំមាសព្រលឹង ទន្ទឹងឡើយណា
ក្រែងម្តាយយាត្រា ទៅហើយចោលចៅ ៗ ម្តាយទៅតាំងទុក្ខ
ឥតឯហៅសុខ អល់ឯកអួលក្តៅ បើបដ្ឋងខាន
ពុំបានណាពៅ ហេតុនេះនឹងទៅ ទៅតាំងទុក្ខា ៗ
កាលណាព្រះបាទ ដៃដេតននាដ ព្រះរាជបុត្រា
ប្រណម្យក្រាបទូល ឥសូរយក្សា ខ្ញុំសូមក្រាបលា
ក្សត្រក្សានធិបតី ៗ នឹងជូនដំនក ដំនើទៅស្រុក
ហេមន្តបុរី ៗ ក្សត្រយក្សព្រមស្រេច សម្តេចចក្រី
ផ្តែផ្តាំប្អូនស្រី សង្សារស្នេហា ៗ ទៀងទើបព្រះអង្គ
លុតលើកកំបង់ ថ្វាយបង្គំលា ស្តេចវិលវិញដល់
មណ្ឌលហើយណា គង់ព្រះពន្លា ពុំលង់ឡើយហោង ៗ
ស្តេចឲ្យរៀបរោះ ដំរីរទេះ ទព់ថ្មើរជើងផង
លុះបានពិលា ក្សត្រាប្រុះប្រុង នាំនាងនាដផ្គង
ឡើងគង់គុជ្ឈសារ ៗ រីព្រះរាជបុត្រ ថ្ងៃថ្វាពិសុទ្ធ
សោកហៃបិតា ស្តេចគង់គុជ្ឈន្ទ នរេន្ទ្រក្រៀវក្រា
មុខមន្ត្រីត្រា ជាជួរខ្ទាប់ខ្ទាន់ ៗ ឯស្តេចប្រាំបី
រយគង់ដំរី បរមុខប្រិនជាន់ សុត្ថានហៃ ៗ

គ្រឿនៗណាស់ណាន់ ក្សត្រថ្ងៃសោកណា ដល់ចុងសោមា ៗ
កន្ទុះរីខស្ពាត់ បើកបន្ទូលថ្វាត់ ទឹងរាជទសព្រ
ហៃកូនត្រកាល សង្ក្រាស្នេហា ស្លទ្ធីយចូរផា
វិលវិងទៅថ្កាន ៗ អាសូរក្សត្រិយ៍ សំសោយសោភគិ
លាពលទន់ពុំក្រាន្ត ទាំងក្សត្រិយគ្រា ថ្ងៃថ្កាប្រធាន
ទន្ទឹងក្រៃងមាន ជម្ងឺរោគា ៗ ព្រះរាជទិរស់
ក្រាបបង្គំត្ដោះ ពីព្រះរាជា ព្រមព្រះបំណង
ចិត្តចង់យាត្រា ថ្កានរាជពន្ទីតា នាងនាងឃ្លាតឆ្ងាយ ៗ
ហើយស្តេចប្រណម្យ ថ្វាត់ថ្វាយបង្គំ លុំអុតទិនកាយ
ផាទបទលុតលា ក្សត្រាពន្រាយ ជលនេត្រហូរខ្ចាយ
អួលអន្ទកាត់ណា គង់គុជ្ជន្ទជ័យ ឆាត់ធំស្កិមស្កៃ
វិលវិងយាត្រា ត្រឡប់មកក្រោយ ដល់ជួបប្រាថ្នា
ទូលក្រុងអាសុក ដោយដំណើរវែង ៗ ហើយស្តេចយាត្រា
ថ្កានសុវណ្ណា ពន្លកថ្ងើមថ្ងៃ ស្តេចគង់នាងថ្វាយ
កកាយល្ហមល្ហៃ អរឯងពេកក្រៃ ឥតឯទុបមា ៗ
សម្ទះស្រាកស្រួល ក្រាបទូលសាកសួរ ពីព្រះមាតា
ព្រះអង្គនិយាយ ប្រាប់ប្រាយបរចា សួរសងប្អូនគ្នា
អស់អាថិសេចក្តី ៗ សព្វគ្រប់ហើយណា ចុមព្រះប្អូនគ្នា
រួមរក់មេត្រី ដើបថៃរសស់អង្គ ប្រិត្តិយន៍ឥន្ទ្រី

ក្រញួក្រុងបេត្តី ស្និតស្នាលស្នេហា ៗ រីឯព្រះបាទ
ធម្មិកនាថ ស្តែងស្តេចលីលា ពីក្រុងសីហុន
ឆ្ងាយពន់ពេកណា ខែមួយក្សត្រា ចរចូលនគរ ៗ
ស្តេចឡើងប្រាសាទ ប្រសើរស្អាតស្អាត មូលមួយទូរបរ
វិចារពេញត្រៀបត្រា មហិមាកុះករ គាល់ព្រះភូធរ
អនេកគណនា ៗ ស្តេចតាំងប្រាំបី រយអគ្គវិទ្ធី
ប្រណាម្យទូលថា បពិត្រសូមទាន ស្តេចមានមេត្តា
យើងខ្ញុំក្រាបលា ទៅស្ថានទីខែ ៗ ធម្មិករាជា
ព្រមព្រះចិន្តា បើកស្រេចហើយនៃ ទ្រង់ព្រះរាជទាន
ធនធានថ្លៃៗ ស្កប់ស្កល់ចិត្តក្រៃ គ្រប់អង្គក្សត្រា ៗ
ទោះតាំងមន្ត្រី ពលពាលផងក្តី សឹងបានគ្រប់គ្នា
ស្រេចចរចេញប្កាន ទៅស្ថានអាត្មា សាយសព្វទិសា
ទីទៃទៅហោង ៗ យើងនូវស្រដី ដៃជេតភូមី
នាងសុវណ្ណា ស្តេចសោយសម្បត្តិ រម្យរង្គយក្សា
សឹងហុនសេមា ឯងឥតភ័យផង ៗ ស្តេចតែងឡើងទៅ
បំរើគាល់ហៅ ក្សត្រិយក្ខប្រះប្រឹង អាសុរិនរាជា
ករុណាឥតហ្មង រួមរក់សុខត្រង បុត្រពីរអង្គា ៗ
ស្តេចសោយរាជស្កល់ សុខគន់មណ្ឌល ពលពាលយក្សា
ត្រៀមក្សាន្តពន្ទ្រាយ សប្បាយក្តាត់ណា ដោយបុណ្យក្សត្រា

បណ្ណាល័យជាតិ

ក្សត្រិតីរពង្ស ៗ ឥតក្តីកង្វល់ អំពើអំពល
ទីទៃគ្រប់អង្គ សម្បូណ៌សម្បត្តិ ប្រើនក្តាត់នាគង្វ
នគរភិមុខ គល់គាប់ប្រពៃ ៗ រីកាល្អោះណា
សម្តេចឥន្ទ្រា នរិន្ទ្រហោមតែ ស្តេចទ្រង់ចិន្តា
កង្វព្រះហឫទ័យ អាត់អធ្យាស្រ័យ ដឹងដោយប្រាជ្ញា ៗ
យល់ជាទឹងមាន ហេតុហើយមិនខាន ទ្រង់ព្រះករុណា
អាសូរទេវី ស្រីសុវណ្ណា នូវព្រះភជា
ដៃដេតកូម៉ី ៗ ព្រះឥន្ទ្រគិតគណ ស្តេចទៅមិមន្ត
ទេវបុត្រសួស្តី គឺអង្គតថា គតជាជិនស្រី
ច្បុះច្បងជាតិ វរពុទ្ធពង្សា ៗ បពិត្រអ្នកមាន
បុណ្យន្ទើយសូមតាន អាភធនា ចុះចាប់បដិ
សន្ធិជាតិជា បុត្រសុវណ្ណា ដៃដេតកូធរ ៗ
សម្តេចម្បូរលី ទទួលនូវនិ មន្ត្រហើយត្រេកអរ
ហៀវហោះស្រេចស្រុត ច្បុតវាកបរ ដល់ដែននគរ
ដៃតដេតភជា ៗ ចូលចាប់ប្រដិសន្ធ ទឹងព្រះសូនតន់
នាងសុវណ្ណា កង្វពត្រីស្បាត់ ស្រីវតន៍និទ្រា
យល់និមិត្តជា អស្ចារ្យក្តាត់ហោង ៗ ទ្រង់ព្រះសុបិន
យល់ហាក់ព្រះឥន្ទ្រ កោសីច្បុះច្បង បើកបរភជរត់
ច្បុតមកផ្គង ដល់ដីដូចប៉ង អញ្ជើញដោយ្យា ៗ

ឡើងលើកដរត់ កន្ទេលប្រឿងព្រាត់ ទៅតែត្រឹមរូប
យល់ដូចព្រះបន្ទូ សោកណាស់ដ្រះថ្លា ចូលចាប់ហត្ថា
នាងនាដកល្យាណ ។ នាំនាងយាត្រា ប្រពាធអត្ថា
ព្រៃព្រះហេមពាន សឹងដូចព្រះរា មហិមាហៅហាន
ត្រកន់បីប៉ាន ចាក់បរបេញឆ្ងាញ ។ នាងសោកនាងយំ
ព្រះហស្តផាលផុំ ទ្រូងទ្រុឌស្ញើផ្ងាយ អាឡៃបន្ទ្រូ
ថ្ងៃថ្លាពន្រាយ ទឹកនេត្រហូរខ្វាយ តាមទៅសោះសា ។
ទាន់ហើយក៏កាន់ ដំណើមយកបាន បន្ទួបែងវេហាស៍
វិលវិញមកស្ថាន គិមានអាត្មា ដូចកាលសត្វគ្រា
ពីមុនមកហោង ។ ស្រេចហើយធិតា តើនបាកនិទ្រា
កែកិតកន្ទង ញ័រអស់អគ្គា កគ្រាសៅហ្មង
ពុំបេញស្សូរសង ស្បៀមស្ងាត់បរវារ ឯព្រះរៀមរាក់
ស្តេចយល់ព្រះកន្ត្រ ព្រះប្អូនពុំងារ ក្រៀមក្រមស្រពោន
អាក់អន់សោះសា ស្តេចលួងលោមថា ហៃមាសមិត្តបង ។
ហេតុអ្វីប៉ះណា មិនដូចសត្វគ្រា រៀងមកមួយដង
ប្អូនអន់ចិត្ត ពាក្យពេជនោះផង ប្រសូនសាសង
ប្រាយប្រាប់រៀមរា ។ ក្សិណ នាងនារី ផនអញ្ជលី
ព្រះរៀមរាជា ទូលតាមនិមិត្ត ឯងឥតសង្ការ
សម្តេចរាជា ជ្រាបព្រះហឫទ័យ ។ ស្តេចពិតពុំយល់

ឆ្ងល់ហើយរឹងឆ្ងល់ ប្លែកក្រៅវិសេស ក្សិនព្រះភូធរ
ចេញចរឃ្លាឃ្លៃ ដល់វេនរត់ថ្ងៃ ដណ្ដឹងហោរា ។
ហៅហោរាទាំងឡាយ ឲ្យគន់គូរទាយ សុបិនដេយ្យា
និមិត្តចំឡែក ឆ្ងល់ពេកក្ដាត់ណា ស្ដេចប្រាប់ហោរា
ដោយដំណើរនៃ ។ ហោស្ដាប់ព្រះបន់ ទូលទើបហោគន់
ដោយក្បួនសិលសៃ ហើយទូលព្រះបាទ ននាដចៀសវៃ
បពិត្រក្សត្រថ្លៃ ឥស្សូរសិរសា ។ រីព្រះសុបិន
យល់ដូចព្រះចន្ទ គង់ពងរង្គ គឺព្រះភូធរ
ព្រះវរបិតា នឹងឲ្យសេនា មុះមកដល់កាយ ។
អញ្ជើញព្រះអគ្គ ទាំងពីរទៅគង់ នគរឯងនាយ
រីឯព្រះចន្ទ សោភ័ណពន្លាយ បើដោយខ្ញុំទាយ
និមិត្តនេះណា ។ នឹងមានពងបុត្រ ប្រាណប្រុសប្រាកដ
ទ្រង់រិទ្ធិបេស្ដា តែនឹងលំបាក ចរចាកឃ្លាតឃ្លា
ស្មើក្ស័យជន្មា ឯកឯងជាមួង ។ រីព្រះពាហូ
តឹកដសត្រូវ ប្រមាទប៉ុនប៉ង ឯព្រះជិទី
ក្សត្រិបង្សៈបង្ស ស្ដេចតាមទៅហោង ទើបបានបុត្រា ។
នាំវិលមកឋាន គង់នូវនាស្ថាន សឹងហុនេះណា
បានគ្រងសមាត្ដិ មេរ្យរដ្ឋប្រជា ទាំងបីភាគ
ប្រាកដក្ដាត់ហោង ។ ហើយមានតបៈ ជោគជ័យជំនះ

ឥតអ្នកស្មើផង ជាក់ជាឥស្សូរ កំពូលប្បុះប្បុង
លើសលែងលោកផង ទូរនាំងទិស្សៈ ៗ ព្រះបាទជៀសវៃ
ស្តេចស្តាប់សូមៃ ហោះហើយក្សត្រា ទ្រង់ព្រះកជទាន
ធនធានជា ៗ រង្វាន់លោព កាលណោះឯងហោង ៗ
ចាប់ដើមពីថ្ងៃ នោះនាងនាដថ្ងៃ ស្រីស្រស់ទងវង
នាងទ្រង់គភ៌បុត្រ ពីសុទ្ធឥតហ្មង រីកាល្ហោះហោង
ឯអគ្គក្សត្រា ៗ ស្តែងស្តេចពិភាក់ សួនគ្រងរៀមរាក់
គភ៌ពដពន្ធិតា គោះសោយគោះស្រង់ សឹងផ្ទុំសេក្យា
ប្រុងប្រាណគ្រប់គ្នា ខ្លាចខ្លួនទទៃ ៗ គោះទឹកត្រជាក់
ពេកហើយខ្លាចអ្នក និតនៅក្នុងផ្ទៃ ទឹងរងាក្តាត់
គន់គិតគ្រប់ក្រៃ ក្តៅពេកសោតទៃ នៅពុំសប្បាយ ៗ
គោះល្ហឹងគោះប្រែ ជូរចត់សោតទៃ ហើរហាងចាំឡាយ
ពុំឲ្យក្សត្រី ទេវីធោមធាយ ខ្លាចក្តៅក្រហាយ
ដល់បុត្រពុំងា ៗ គោះបីបើនាង ទឹងស្តេចយាសយាង
ឡើងចុះក្តីណា មានអ្នកថ្នាក់ថ្នម បីបមដេយ្យា
ក្រែងព្រួយអគ្គា សម្តេចមហេសី ៗ អកយាយចាស់ទុំ
បំរើជិតជុំ ប្រយ័ត្នប្រក្រដី មិនមានសៅហ្មង
សួនគ្រងបេត្តី ស្តេចរងប្រណី ព្រះប្អូនស្នេហា ៗ
រីកាលណោះហោង ស្រីស្រស់ប្បុះប្បុង ទ្រង់ព្រះបិត្តា

ព្រួយព្រះហឫទ័យ ស្រីថ្ងៃមហិមា ទឹងគកិអាត្មា
ពេកពន់កន្លង ៗ គិតដល់មាតា ឪអទិច្ចា
ឥតញាតិផៅផង បើនឹងប្រសូតិ រាជបុត្រស្នងគ្រង
អ្នកណានេះម្ដង ទឹងស្មើមាតា ៗ នាងគិតនាងទ្រង់
កន្ទ្រងលុះលុង អាណិតអាត្មា កីលាពតឥតល្ហែ
ក្រិនឯកក្រត្រា ស្ដេចថ្នមធិតា លួងលោមស្រដី ៗ
ហៃមាសសង្រ ខ្ញុំមចិត្តត្រកាល ត្រកូលជាតី
ហេតុម្ដេចនាងថ្ងៃ កន្ទ្រែងសែនថ្វី ប្រការគល់អ្វី
ណាមេមាសថ្លៃ ៗ ក្រែងអ្នកឯណា ពោលពាក្យបរពារ
ឲ្យអន់ព្រះទ័យ ប្ដូមួយស្រឹង្គា បរិពោរសព្វថ្ងៃ
ធ្វើខុះម្ដេចនៃ នាងសោយសោក្កា ៗ ប្ដូមួយអញបង់
ឯងអាចឲ្យគ្គង ចិត្តទៅត្រង់ណា ប្ដូរទៅតាយថែង
ថ្វាថ្ងៃរស្ព៉ សោះរៀមសង្កា ចិន្ដាណាពៅ ៗ
ក្សិណ្ណាះសុវណ្ណា លើកករន្ទួ ប្រណម្យទូលពៅ
ព្រះបាទព្រះបង នេះម្ដងឥឡូវ ឥតអ្នកណាក្វ
ខានខុះចិន្ដា ៗ តែខ្ញុំថប់សល់ ប្រសិនបើដល់
ប្រសូតិបុត្រក្ញារ ឥតផៅញាតិពង្ស ឯកអគ្គិអាត្មា
នឹងយំល់នរណា ដូចព្រះជិទី ៗ ហើយនាងនិយាយ
ទូលក្សត្រពន្រាយ រៀបរាប់អំពី មុនមកនោះណា

នូវនារី យើងបានស្រដី សួររៀបហើយណា ៗ
នាងទូលសព្វគ្រប់ រិះរិងថៃថប់ ក្នុងចិត្តឈឺផ្សា
ចតីនេះទៅ ពុំដឹងយ៉ាងណា ហេតុតៀវរើក
ទើបឃ្លាឃ្លាតឆ្ងាយ ម្លេះសុំពុំបាន វិលវិងទៅឋាន
សងគុណអ្នកម្ដាយ នូវអ្នកឪពុក នូវឯស្រុកនាយ
បាបម្ដេចអម្បាយ តាមតាន់ប្ចេះណា ៗ បើនៅបុរី
មានព្រះជនី ជនកក្សត្រា ត្រកូលរាជវង្ស
សឹងទ្រង់មេត្តា នេះម្ដងខ្ញុំមហា ថប់ពន់ពេកក្រៃ ៗ
ស្ដេចស្ដាប់ទេវី ទើបព្រះភូមី ឱបភក្ត្រស្រីថ្លៃ
មានព្រះមធុរៈ សួរសងស្ងួម៉ែ ត្រេកត្រាស់ថាហៃ
នាងសុវណ្ណា ៗ កុំសោយសោកឡើយ ព្រលឹងបងអើយ
គិតតែមាតា បើបានប្រសូតិ បុត្តមកកាលណា
សឹមបងយាត្រា ជូនចៅទៅហោង ៗ ឥឡូវនេះនៃ
គតិមិញពេញផ្ទៃ កុំមាសស្នេស្នង គិតព្រះបិតា
មាតាឡើយហោង គានាលើបង កុំប្អូនបារម្ភណ៍ ៗ
ក្សត្រីត្រកូល ស្ដាប់ព្រះបន្ទូល ក្សត្រថ្លៃឧត្ដម
ស្រីរតនបវរ លើកកបង្គំ ក្សេមក្សាន្តភិរម្យ
ល្ហៃល្ហើយឧក្ខា ៗ ស្ដេចនាំស្រីថ្លៃ ចរចេញគង់ឮ
រាជរត្នបនា នូវអស់ព្រះស្នំ ចាស់ទុំគៀបត្រា

កាលោះវីទ្យា ចូលជិតទេវី ៗ បានបៀតចិតខាង
ហើយទើបទូលនាង បពិត្រក្សត្រី ខ្ញុំសោកទម្ងន់
បុត្តតន់ពីសី អ្នកមាសស្រដី ខាយទុកច្រើនក្តាត់ ៗ
កាលស្តេចមកមុន នោះនាងស្រីតន់ ជាខ្ញុំនឹងក្សត្រ
ពិតមែនជាប្តី បេត្តីបរត្ន ម្ចាស់សើយមែនក្តាត់
គួរខ្លាចសោះសា ៗ នាងត្រសំដី ពាក្យវីទ្យាវៃ
ផ្ញុញផ្គាល់ហ្នោះណា ជាក់មុខត្រងើប ស្មើសើបស្មើជា
អៀនឱនក័ក្តា ក្រាស់ក្រៃកកន្ទួង ៗ ជាហៃវីទ្យា
ថែងចេះចរចារ ចំអន់លេងលង ហាក់អញ្ចេះណា
ជាគ្នាស្មាហោង ពុំកោតប៉ុនល្អង តាមតែនឹងថា ៗ
ក្បិននាងស្រីរត្ន ចាប់បានរំពត់ ដេញពាយវីទ្យា
ស្តេចយល់នាងនាជ វិរត្នស្នេហា ពាយបញ្ចាក
ក្បិនក្សត្របះបង្វ ៗ ស្តេចលួងលោមឃាត់ ចាប់បានរំពត់
ពីព្រះប្អូនហោង ហើយពរវីទ្យា ក្សត្រាសាសង
ខុសអ្វីនេះម្តង ធ្លាក់ទោសដល់ប្រាណ ៗ នៃនិទាននេះ
យើងបញ្ឈប់ស្ទុះ ពុំទាន់និទាន នឹងថ្លែងពីអង្គ
ធម្មិកប្រធាន សប្បាកល្យាណ ជាព្រះមាតា ៗ
ពីរពង្សក្សត្រថ្ងៃ ក្នុកព្រះហឫទ័យ គិតតែបុត្រា
ទន្ទឹងរើងបាត់ ស្ងប់ស្ងាត់មហិមា ពុំមានអ្នកណា

មួយមកឡើយនៃ ទ្រង់មានវាចា ឱមាសពុំការ
ពន្ធកថ្ងើមថ្ងៃ កូនអើយឪពុក ទល់ទុក្ខក្រោយក្រែ
រឹងរែតអាឡៃ បាបុត្រស្នេហា ៗ ឯព្រះជនី
សព្វាទេវី សឹងសោយសោក្កា ទួញទៅរាជបុត្រ
នេត្តទ័យព្រ កូនអើយម្ដេចបា បោះបង់លុះក្ដាត់ ៗ
ក្រែងកើតពេគ្គា ព្រាធិនិន្ទា ដម្ងឹដម្កាត់
ប្តូមួយរង្វេង បិត្តឯងភ្ញាំងភ្ញាត់ ដោយសង្រាសត្វ
មាតុគ្រាមតណ្ហា ៗ ក្មេចឪពុកម្ដាយ ក្មេចស្រុកឯអាយ
ពិតពុំនាំពា នូវសៀមកន្ដើយ ប្រងើយសោះសា
ឲ្យយើងកល់គ្នា ទុក្ខទន្ទឹងនៅ ៗ រីកាលនោះណា
ព្រះវរបិតា ធិរាជទោមទៅ តែងព្រះរាជសា
ឱគ្កាទូលទៅ អញ្ជើញចមទៅ ដៃដេតបុត្រក្មា ៗ
លាយលាកអក្សរ ពីព្រះកូធរ មាតាបិតា
ផ្ញើមកអញ្ជើញ រាជាឪសា នូវនាងជាយា
រាជបុត្រពន្រាយ ៗ ដ្បិតពីក្សត្រា ទ្រង់ព្រះរាជា
ពិតពុំសប្បាយ អំពើអំពល់ ពុំស្គាល់ព្រះកាយ
ដ្បិតបុត្រពោមធាយ ចាកចំបែងបង់ ៗ ឥឡូវនេះណា
បើពុំយាត្រា ខំខានបង្អង់ សំមាសវលក្ស
អានយល់កគ្គហោង ទាំងពីរព្រះអង្គ ដូចមុនមកណា ៗ

សរសេរសារស្រេច   កាលនោះទើបស្តេច   ត្រាស់ប្រើអគ្គា
មាត្យមួយនានាំ   កិច្ចកម្មអក្ខរ   ដើរដោយមាគ៌ា
ខែ១សោតហោង ៗ   ទើបដល់ដំបន់   នគរសឹងហុន
ដូចចិត្តប៉ុនប៉ង   ហើយឡើងទៅទូល   ត្រកូលក្សត្រប្រង
រាជបុត្រស្នេស្នង   ក្រាបព្រះទ័យ ៗ   ស្តេចទតសំបុត្រ
អួលអន់ស្រយុត   ក្នុងព្រះចិន្តា   រន្ធត់អាឡោះ
ស្រណោះពេកណា   តាំងពីអក្ខរ   មុះមកដល់ខ្ញុំ ៗ
ថាឪអញធ្គន់   យូរណាស់ហើយហោង   បោះបង់បុរី
នូវពីរភជា ក្សត្រាក្សត្រី   គួរគិតប្រណី   ដ្បិតសឹងជាក ៗ
ហើយស្តេចប្រញាប់   ត្រេកត្រាស់បង្គាប់   ព្រះពិលៀងថា
ឲ្យរៀបរពល   សុគលយោធា   ព្រឹក្យនេះនឹងយា
ត្រាត្រេចជាម្តង ៗ   ទើបព្រះភូមី   បរបូលទៃទី
នាងនាថឥតគ្គន់   ព្រះឪសបរបារ   ហត្ថាត្រកង់
អង្គុលប្ដោសខ្នង   សំណោះថ្លែងថា ៗ   ហៃអ្នកខ្ញុំមចិត្ត
ស្មើថ្ងៃមជីវិត   ស្តែងស្លាប់បង់ព   ដ្បិតមានបន្ទូល
រាជសារស្នេហា   ពីព្រះមាតា   បិតានាយនៃ ៗ
មកដល់ហើយហោង   អញ្ជើញរៀមបង   មូលមួយស្រីថ្លៃ
ពីព្រះបង្រះបង្រង   រីងរង់ទុក្ខក្រៃ   យូរលង់ទឹងកៃក្យ
តុំយល់កត្រា ៗ   មួយប៉ើទឹងចាក   បរបញ្ជលះលាក់

ទឹងមាសពំនឹរ រីឯគតិថ្ងៃ ពេញផ្ទៃបេះណា
តាមតែប្អូនគ្នា គិតម្តេចនេះម្តង ៗ នាងនាថសុវណ្ណា
ប្រណាម្យទូលថា បពិត្រអ្នកបង បើទឹងស្តេចទៅ
លំនៅនាយហោង យកប្អូនទៅផង ជាខ្ញុំបាទា ៗ
សព្វថ្ងៃប្អូននៅ គ្រាន់បានកក់ក្តៅ ដោយព្រះពជា
អម្ចាស់សិរសី ប្អូនស្រីនេះណា ម្តេចទឹងឲ្យឃ្លា
ឃ្លាតទៅទីទៃ ៗ បើនៅកំព្រា ម្នាក់ឯងឯកា
ព្រាត់ព្រះបោមត្រៃ ទឹងសោកទឹងរងើ ទុក្ខផងក្រាស់ក្រៃ
សំប្អូនទឹងខ្យៃ ជីវិតមរនា ៗ ស្តេចស្តាប់ប្អូនស្រី
ព្រមព្រះហាទ័យ ទើបស្តេចលីលា ព្រះអគ្គនាំនាង
យាសយានយាត្រា ទៅឋានបិតា បោមចៅអាសុរ ៗ
ស្តេចលើកកំបង់ វរនាថផង់ ឥនអញ្ជលី
ទើបទូលព្រះបាទ ននាថធិបតិ ដោយដំណើរតី
ព្រះវរបិតា ៗ បពិត្រព្រះអគ្គ ពិសេសសូមទ្រង់
ព្រះរាជករុណា ដ្បិតព្រះជិនក ទល់ទុក្ខសោកា
តាំងព្រះមាតា សង្រែងក្តាត់ហោង ៗ មានព្រះឫទ្ធិរ
ឲ្យនាំពជសារ មុះមកនេះម្តង កងណាយណាកខាន់
គប់គ្រាន់សោតហោង ឲ្យខ្ញុំបរផ្គង ទៅឋានពជា ៗ
ថាបើខ្ញុំទាន យូរយល់ពុំបាន ឃើញព្រះភក្ត្រា

សំពីរព្រះអគ្គ   បាត់បង់ជនមា   ហេតុនេះខ្ញុំលា
សម្តេចបក្រើ ៗ   នាងសុវណ្ណា   សោកសូមក្រាបលា
ទៅថ្វាយវន្ទី   ហើយនឹងក្រឡាប់.   វិលឆាប់មកខ្ញី
ដូចដើមប្រក្រតី   ជាខ្ញុំបាតា ៗ   ក្សត្រយក្សស្លាប់ស្ដែង
រាជបុត្រទូលថ្លែង   អង្វរលោមលា   ព្រះអគ្គអន់អួល
រំជួលចិន្តា   សែនសោយសោកា   គនគិតអាល័យ ៗ
ជាទុអញ្ជ៉   ពុតតាតពន្សដៅ   សន្តានដទៃ
មានតែធីតា   ពិសាររថ្មើមថ្លៃ   កេ្សាសពូថ្លៃ
ចិញ្ចឹមសូនគ្រង ៗ   នាងសុវណ្ណា   លើកកន្ទា
ប្រណម្យយំផង   ខ្ញុំពុំបង់ឃ្លាត   ព្រះបាទនេះម្តង
គុណជូនកន្ទង   លើសលើលោកា ៗ   ខ្ញុំនឹងសូមសង
ព្រះគុណនេះម្តង   ឲ្យអស់ចិន្តា   ខ្ញុំរង់ទុក្ខធ្ងន់
ពេកពន់ក្តាត់ណា   ក្រោយខ្ញុំយាត្រា   ទៅហើយបក្រើ ៗ
ក្រែងមានភេតា   ហើយតែនរណា   នឹងដូចបុត្រី
នឹងមើលថែទាំ   កិច្ចការក្រិះសាយ   គោជកស្តអ្វី ៗ
ដូចកូននេះណា ៗ   ឥតលុះសោកសល់   ដ្បិតព្រះទសពល
ទាំងពីរអគ្គា   ស្តេចពុំសប្បាយ   នូវនាយកំព្រា
ហេតុនេះខ្ញុំលា   ហើយវិលវិញឋាន ៗ   ស្តេចស្តាប់បុត្រី
ហើយក្រុងអាសុរី   បន្ទូលសងសារ   ឱមាសថ្មើមថ្លៃ

ប្រែពតល្ងិយាណា  ហេតុបាបបុរាណ  កម្មកាលព្រេងនាយ ៗ
ឲ្យយើងចម្បែង  ចរចេញលះលែង  ទីទៃស្ថានឆ្ងាយ
ទទ្រង់រងទុក្ខធ្ងន់  គានស្មើនឹងថ្លាយ  មិនមានរសាយ
ដល់តិចឡើយណា ៗ  ទុំពុកប្រណី  កូនស្ងួនពីសី
សោកសង់ទ្រង់តក់  កាលបើសម្រាល  កូនកាលឯណា
ឥតញាតិការ  សន្តានផៅផង ៗ  នឹងបានពិភាគ
ស្ងួនត្រង់រៀមពក់  សោកសាទេះម្តង  កូនទើយទុំពុក
ឥតសុខឡើយយោង  សំពុំរលង  ពីក្តីមរនា ៗ
ប៉ុនប៉ង់សព្វថ្ងៃ  ទោះបីទឹងខ្សែ  ជនជាតិជក
ទុំពុកនៅផ្ទើ  ទោចលើស្ងួនក្សា  ទាំងពីរអង្គ
លើកសព្វខ្លួនព៌ ៗ  ដៃដេតបក្រើ  ទទនអង្គអភិ
រាតវិវន្ទា  សូមបានព្រះអង្គ  ទ្រើសទ្រង់កូរណា
កុំស្តេចសោកា  ទលទុកឡើយហោង ៗ  ទៅពុំយូរគាត់
ខែមួយហើយថ្លាត់  វិលវិញមកផង  កុំព្រួយបិត្តា
ក្សត្រាបព្ទាសបង្វង  ធ្វើមេថ្មេះម្តង  ព្រះគុណធ្ងន់ក្រៃ ៗ
ឯក្រងអាសុក  ទបបុត្រប្រសា  សាសង់សូម៉ៃ
ពុំអាចទឹងឃាត់  បុត្រតេឡើយខែ  បើកតាមព្រះទៃ
បុត្រថ្ងៃប៉ុនប៉ង់  ឯក្រងយក្សា  ឲ្យអស់សេនា
មុខមន្ត្រីផង  ទៀបរេហ៍ហត្ថី  ពាជីសោតហោង

រាជបុត្រស្នែស្នង ស្ដេចនឹងលីលា ៗ ទើបបុត្រពីរពង្ស
បង្គំទូនអង្គ ព្រះវរបិតា ត្រឡប់វិលឋាន
ទីស្ថានអាត្មា ស្រាប់ស្រេចហើយណា ស្ដែងស្ដេចពុង្សង ៗ
ប្រដាប់អាត្មា ទង់គ្រឿងរចនា សីហនាថឡើងគង់
លើកុជគុជ្ឈន នរេនទ្រើសទ្រង់ នូវនាងវរវង្ស
នៃបទឹងកជា ៗ ក្សត្រកិលៀង ៤ តែងរក្សាសួន
ហែអង្គតៀបត្រា អន្ដាប់នោះនៃ ទាំងនាងវិទ្យា
ជិតដោយធិតា មិនមានឃ្លាតឆ្ងាយ ៗ ក្ងឹងក្ងស់លយុំ
សត្វក្ងិនរងុំ ស្រើបស្រួលសប្បាយ ចេញចាកបូរី
ទីទៃស្ថានឆ្ងាយ ពលពាលទាំងឡាយ អាណែកក្រាស់ក្រៃ ៗ
រីមនុស្សនឹងយក្ស ច្រើនពេកអាណាក ពាសពេញទាំងព្រៃ
ដោយបុណ្យព្រះបាទ នរនាថដៀសដៃ នូវនាងនាថនៃ
ត្រកាលកាត់ណា ៗ ក្សត្រថ្ងៃប្រសើរ ស្ដេចដោយដំណើរ
ព្រៃព្រឹក្សអត្ថា ទូតអស់ស្ថានផង ដោយផងមាតា
ឈើឈរសាខា លូតលាស់លំពង់ ៗ ខ្លះផ្លែខ្លះផ្កា
ក្ដាំងងារបូជា រីកពេញសំយុង បក្សីធ្មឹមផ្អាប់
បុះបាប់បោមបុង ខ្លះទុំសុំកុង សំកុកខាងគ្នា ៗ
ខ្លះហើរទៅទុំ ទុំហើយយាសយុំ យុំផ្សេងភាសា
ខ្លះស្ងៀមស្ងប់ស្ងួល លើចុងរុក្ខា ផ្អៀងផ្អងបរបារ

ក្រញូក្រកន៏និតនៅ ៗ ខ្វះពាំអាហារ បៀមបានត្រអាល
បញ្ញកកូនចៅ ខ្វះសិតស្លាបហាល កណ្ដាលថ្ងៃក្ដៅ
ខ្វះហើរហួសទៅ ផ្ទុកផ្ទះសោះសា ៗ ស្ដេចត្រាច់ដោយដង
ព្រៃព្រឹក្សផ្សែលង ផ្ទង់ដោយអគ្គា ព្រះឱសរៀបរាប់
ប្រាយប្រាប់ប្អូនភា សរសើរបក្សា បក្សីពាំងទ្រាយ ៗ
បរត្រេបលុះលុង ខែ ១ ដល់ចុង
ហេមន្តព្រាយ សង់ព្រះបម្វា ម្ហូមាប្រញាយ
នាំនាងតាមនាយ ចូលបតហើយណា ៗ ហើយស្ដេចឡើងទៅ
ទូលព្រះមហាបៅ ដាព្រះបិតា ស្ដេចប្រាប់សេចក្ដី
ពិតពីបុត្រា អរស័តទបហា ត្រាស់ប្រើមន្ត្រី ៗ
រត់រះមកថាន ទទួលក្សត្រកូន នូវនាងស្រ្តី
តាំងនាងប្រាំពីរ អគ្គានោះក្ដី សឹងចរបញ្ចេញ
ទទួលភជា ៗ អាមាត្យនាំនាង ប្រាំពីរយាសយាង
ត្រេបដោយមាគា ដល់ដូចបំណង ហើយហោងម្ហូមា
ចចូលវាំង ពីក្សត្រស្នូរស្ដី ៗ នាងយល់ព្រះបង
ស្លាលស្និតត្រប់គ្រង់ នៃបងនឹងក្សត្រ បង់ចិត្តចិន្តាន
ប្រទានចក្រ តឹមុះផ្កាស្រី ថៃងបេះមាយា ៗ
ធ្វើហាក់ស្នេហ៍ស្និត អរអស់ពីចិត្ត មិនមានសង្កា
តែផ្ទង់ពង់ពោះ មិនបោះឡើយណា គង់នឹកគិតថា

ទោះទេនេះមុន ៗ ក្សត្រិក្សត្រា សាកសួរបរិវារ
ស្ពានស្ពោះពិតហោង មិនដឹងគលកិច្ច កន្ទ្បបតទូង
គេគិតប៉ុនប៉ង បៀតបៀនអាត្មា ៗ ស្រេចទើបព្រះអគ្គ
នាំនាងឡើងគង់ ដំរីលីលា ស្តេចដល់ប្រាសាទ
ព្រះបាទក្សត្រា បង្គំវន្ទា ពីព្រះនរបតី ៗ
ព្រះវរបិតា ទូលនាងសព្វា អរទិបបុត្រ
ទូវរាជទិវស ប្រាណប្រុសពីសី ថ្នាក់ថ្មមបេតី
វត្ថិវតអគ្គា ៗ ប្រែបោសប្រែបក ព្រះលឹងនៃអ្នក
មាសមិតពិសារ ម្តាយឪរៅយក មាសមកម្តេចប៉ា
យូរពេកក្តាក់ណា ម្តាយទទឹងនៅ ៗ ឯអគ្គរាជបុត្រ
ទិនកាយលំអុត សោសង់ទូលទៅ មាតាបិតា
ក្សត្រាចោមចៅ បាទជាយូរនៅ ផូវឆ្ងាយមហិមា ៗ
ហើយស្តេចចូលទ្ធ ពីក្សត្រអាសុរី ផ្តៃដាំផ្តជា
សព្វគ្រប់ពុំផ្សេង ប្រហែសឡើយណា ព្រះវរបិតា
ជាបព្រះហារ៊ៃ ៗ ស្តេចមានមេត្តា រាជបុត្រប្រុសា
សួនគ្រងសព្វថ្ងៃ ពុំដែលឲ្យអាក់ ប៉ាំងថ្នាក់ព្រះទៃ
ឲ្យរៀបចងដៃ ពីរពង្សបុត្រក្សា ហើយអត់សេក
ថ្កល់ថើងជាឯក ឥស្សរភាព គ្រប់គ្រងសម្បត្តិ
រមេរតស្នេហ្នា ស្នងព្រះបិតា តាមព្រះវេណី ៗ

ស្រេបទើមព្រះជាំង ឲ្យផ្ទុំប្រាសាទ ប្រសើរសួស្តី
ក្បាច់ក្បូរព្រានព្រាយ ឆាឆាយរស្មី ថ្វាយបុត្រពីសី
ទាំងពីរអគ្គារ ៗ ការលោះព្រះអគ្គ ស្ដែងស្ដេចទៀងគង់
ប្រាសាទសោភា នូវនាងនារី ស្រីគ្គាបរិពា
សុំស្និតស្នេហា ការណៃកម៉ីមាន ៗ យើងនូវស្រេបី
ឯអគ្គក្សត្រិ ប្រាំពីរកល្យាណ នោះនាងតែងទៅ
គាល់ហៀកក្សត្រកក្សាន សព្វថ្ងៃមិនមាន ជាប់មួយទេក ៗ

(ខ្សែ ៣ សង្ខេបតែប៉ុណ្ណោះ)

ខ្សែ ៤ ដើម ស្ដេច ដៃដេត ទ្រង់ផ្ដាបថា

នាងទាំង ៧ នាក់ស្អប់នាង បំប៉ាំថាន

ទើបទ្រង់យាងទៅលួងលោម

កណ្ដាល នាងទាំង ៧ធ្វើកល់ឲ្យស្ដេចចេញទៅទាក់ដំរី

ចុង ស្ដេចដៃដេតបំបរបង់នាងបំប៉ាំថានឲ្យចេញពីនគរ

# សៀវភៅដែលផ្សាយចេញពីគេហស្ថាន គឹម-គី

| | | |
|---|---|---|
| បកិណ្ណកបរិត្ត . . . . . . . . . . . | ១ សៀវភៅថ្លៃ | ១២'០០ |
| ទេវតាគាសិតនឹងពុទ្ធភាសិត . . . . . . . | ,, | ៨'០០ |
| សម្ភារសិក្ខាបទ គោលសិក្សាជំនួយធម្មវិន័យ . | ,, | ១២'០០ |
| វេយ្យាករណបាឋទី ១ . . . . . . . . . . | ,, | ១៨'០០ |
| ,, ,, ទី ២ . . . . . . . . . . . . | ,, | ១៧'០០ |
| វេយ្យាករណ៍ខ្មែរ . . . . . . . . . . . . | ,, | ១៣'០០ |
| លេខទៀរ . . . . . . . . . . . . . . | ,, | ១៥'០០ |
| បត្តិទានាទិគាថា គឺឥមិនាប្រែ . . . . . . | ,, | ៦'០០ |
| ធម្មបញ្ហា . . . . . . . . . . . . . | ,, | ៦'០០ |
| បញ្ញានិទ្ទេស . . . . . . . . . . . . | ,, | ២៥'០០ |
| សមាធិនិទ្ទេសសង្ខេប . . . . . . . . . | ,, | ៣០'០០ |
| ប្រស្នាតិហាបដិបត្តិ. . . . . . . . . . | ,, | ១៨'០០ |
| វិធីប្រែបាលី . . . . . . . . . . . . | ,, | ២៥'០០ |
| ប្រស្នាអភិធម្ម . . . . . . . . . . . | ,, | ២៥'០០ |
| ប្រស្នាត្រៃគុណ . . . . . . . . . . . | ,, | ២៥'០០ |
| សាមណេរវិន័យបញ្ហា . . . . . . . . . | ,, | ១៨'០០ |

សៀវភៅកំពុងបោះពុម្ព ឬ ប្រុងនឹងបោះពុម្ពតទៅ

រឿងដំបងគ្រញូង-ក្បាលគេក-បក្សីចាំក្រុង　　រឿងមេទ័ពឥន្ទ្រីស

រឿងបមក្រពាំងបញ្ចូមត្រពើ　　រឿងព្រះបាទអជាតសត្រូវ

រឿងនិទានទេវទត្ត　　រឿងព្រះសុវណ្ណវង្ស

នឹង សៀវភៅ បាលី-ខ្មែរ ដទៃទៀតជាច្រើន

ការផ្សាយរបស់

លេខ ៨៨ វិថីអែមេក្រង់ ភ្នំពេញ

ជិតរោងកុន ព្រហ្មឫាយ៉ន ពីខាងកើតផ្សារចាស់

---

## សេចក្ដីជូនដំណឹង

បណ្ណាគារខ្ញុំបាទ មានទទួលចងក្រងសៀវភៅ មានជាព្រះពុទ្ធរូប រូបចតផ្សេងៗ គឺព្រះរូបព្រះករុណា ទាំងសម្ដេចសង្ឃនាយកជាដើម ទាំងសៀវភៅធម៌ សៀវភៅរឿង គ្រឿងសរសេរ សង្ឃដិកា ឆាយា សំបុត្រកំណើត កាតកូនសិស្សទាំងសៀវភៅបារាំង-ខ្មែរផ្សេងៗ ជាច្រើនៗ

សូមនិមន្ត ទាំងអញ្ជើញលោកអ្នកចូលជាវចិញ្ចឹម ដោយមេត្រីៗ បើទិញដុំ យកទៅលក់ទៀត ខ្ញុំគិតថ្លៃថ្នាក់ជូនយ៉ាងគួរសមៗ

ព.ស. ២៤៩៦ គ.ស. ១៩៥៣

ថ្លៃ ១២៛០០

) រោងពុម្ព ភិក-គ៏ ភ្នំពេញ (